សមិទ្ធផលព្រឹទ្ធសភា
នីតិកាលទី២ (២០០៦-២០១២)



ចោះពុម្ពផ្សាយដោយ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
ខែមករា ឆ្នាំ២០១២


សម័យប្រជុំដំបូងព្រឹទ្ធសភា
នីតិកាលទី២



សមាសភាព សមាជិកព្រឹទ្ធសភា
នីតិកាលទី២ (២០០៦-២០១២)

ថ្នាក់ដឹកនាំព្រឹទ្ធសភា



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត ជា ស៊ីម
ប្រធានព្រឹទ្ធសភា



សម្តេច ស៊ីសុវត្ថិ ជីវ័ន មុនីរ័ក្ស
អនុប្រធានទី១ ព្រឹទ្ធសភា



ឯកឧត្តម ឆេង ដន
អនុប្រធានទី២ ព្រឹទ្ធសភា

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី២



សម្តេច ស៊ីសុវត្ថិ ជីវ័ន្តមុនីវ័ង្ស
អនុប្រធានទី១



សម្តេចអគ្គមហាធម្មពោធិសាល
កិត្តិព្រឹទ្ធបណ្ឌិត ជា ស៊ីម ប្រធាន



ឯកឧត្តម ទេព ឆន
អនុប្រធានទី២



លោកជំទាវ ម៉ែន ម៉ាលី
សមាជិកា



ឯកឧត្តម ជា ដេជ្ជ
សមាជិក



ឯកឧត្តម ចាន់ គិន
សមាជិក



ឯកឧត្តម គង់ សាវង្ស
សមាជិក



លោកជំទាវ ទី ប៉ូរ៉ាស៊ី
សមាជិកា



ឯកឧត្តម អ៊ុក ប៊ុនឈឿន
សមាជិក



ឯកឧត្តម គង់ គាំ
សមាជិក



ឯកឧត្តម ឈឹម សាខន
សមាជិក



ឯកឧត្តម សាប៊ូ ចាចា
សមាជិក

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត



ឯកឧត្តម សេក សំអៀត
អនុប្រធាន



លោកជំទាវ ម៉ែន ម៉ាលី
ប្រធាន



ឯកឧត្តម តឹម ណាំង
លេខាធិការ



ឯកឧត្តម កង ចន្ទ
សមាជិក



ឯកឧត្តម អ៊ុក គង់
សមាជិក

គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម



ឯកឧត្តម ពៅ សិទ្ធិ
អនុប្រធាន



ឯកឧត្តម ជា ដេដ្ឋ
ប្រធាន



ឯកឧត្តម អ៊ុំ សារិទ្ធ
លេខាធិការ



ឯកឧត្តម ខ៉ាន់ ម៉ាត់
សមាជិក



ឯកឧត្តម ឆាត់ លឿម
សមាជិក

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន



ឯកឧត្តម អ៊ឹង ហួត
អនុប្រធាន



ឯកឧត្តម ចាន់ តិន
ប្រធាន



លោកជំទាវ ហាន សំអាន
លេខាធិការ



ឯកឧត្តម ជ័យ សាផុន
សមាជិក



ឯកឧត្តម ម៉ុង ឫទ្ធី
សមាជិក

គណៈកម្មការមហាផ្ទៃ ការពារជាតិ ចំណាក់ចំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ



ឯកឧត្តម ប៉ុក កុសល
អនុប្រធាន



ឯកឧត្តម គង់ សារាជ
ប្រធាន



ឯកឧត្តម ឡាយ អ៊ីពិសិដ្ឋ
លេខាធិការ



ឯកឧត្តម រស់ ស្រេង
សមាជិក



ឯកឧត្តម ស៊ើយ កែវ
សមាជិក

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន



ឯកឧត្តម ជា គីម
អនុប្រធាន



លោកជំទាវ ធី ឫ៉ាស៊ី
ប្រធាន



លោកជំទាវ ឈូក ឈីម
លេខាធិការ



ឯកឧត្តម ឱក រាម
សមាជិក



ឯកឧត្តម ហុង ឡុហាយ
សមាជិក

គណៈកម្មការនីតិកម្ម និងយុត្តិធម៌



ឯកឧត្តម យ៉ង់ សែម
អនុប្រធាន



ឯកឧត្តម អ៊ុក ប៊ុនឈឿន
ប្រធាន



ឯកឧត្តម ជា សុន
លេខាធិការ



ឯកឧត្តម ថុច ចន់
សមាជិក



ឯកឧត្តម ប៉ើយ កើក
សមាជិក

គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍



ឯកឧត្តម ផ្នាំ ប៊ុនស្រុន
អនុប្រធាន



ឯកឧត្តម គង់ គាំ
ប្រធាន



ឯកឧត្តម តូច សាក់
លេខាធិការ



លោកជំទាវ ឡាក់ អូន
សមាជិកា



ឯកឧត្តម សោម សុផា
សមាជិក

គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី



លោកជំទាវ ពុំ ស៊ីចាន់
អនុប្រធាន



ឯកឧត្តម ឈឹម សាខន
ប្រធាន



ឯកឧត្តម សួន លន់
លេខាធិការ



លោកជំទាវ ព្រំ សិត
សមាជិកា



ឯកឧត្តម ង៉ាន់ ស៊ីឡឿន
សមាជិក

គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់



ឯកឧត្តម ឈិត គីមយាត
អនុប្រធាន



ឯកឧត្តម សាប៉ូ ជាថា
ប្រធាន



ឯកឧត្តម ពុធ ខូវ
លេខាធិការ



ឯកឧត្តម អ៊ុច ធី
សមាជិក



ឯកឧត្តម ពុត ជួប
សមាជិក

សមាជិក សមាជិកា នៅក្រៅគណៈកម្មការព្រឹទ្ធសភា



ឯកឧត្តម អ៊ុំ ម៉ាន្នូរីន
សមាជិក (តំណាងព្រះមហាក្សត្រ)



ឯកឧត្តម រៀវ បណ្ណាការ
សមាជិក (តំណាងព្រះមហាក្សត្រ)



ឯកឧត្តម ឈា ថាំង
សមាជិក



សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី
សមាជិកា (តំណាងរដ្ឋសភា)



ឯកឧត្តម ឡាវ ម៉េងឃីន
សមាជិក

សមាជិក សមាជិកា នៅក្រៅគណៈកម្មការព្រឹទ្ធសភា



ឯកឧត្តម ស៊ឹម កា
សមាជិក



ឯកឧត្តម ហេង ឫ
សមាជិក



ឯកឧត្តម ម៉ែន សារុន
សមាជិក



ឯកឧត្តម ប្រាក់ ចំរើន
សមាជិក



ឯកឧត្តម កុក អាន
សមាជិក



ឯកឧត្តម លី យ៉ុងផាត់
សមាជិក



ឯកឧត្តម ប៉េង ប៉ាត់
សមាជិក



ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី
សមាជិក

ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន



ឯកឧត្តម អ៊ុំ សារឹទ្ធ
អគ្គលេខាធិការ



ឯកឧត្តម ញឹក ឆៃអេង
អគ្គលេខាធិការរង

សញ្ញាសក្តិ និងឯកសណ្ឋានរបស់សមាជិក សមាជិការព្រឹទ្ធសភា

សញ្ញាសក្តិ និងឯកសណ្ឋានរបស់សមាជិកព្រឹទ្ធសភា មានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣១ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០១ ។

១. សញ្ញាសក្តិមាន៥ប្រភេទ ៖

-សម្រាប់ប្រធានព្រឹទ្ធសភា

-សម្រាប់អនុប្រធានព្រឹទ្ធសភា

-សម្រាប់ប្រធានគណៈកម្មការ

-សម្រាប់អនុប្រធានគណៈកម្មការ

-សម្រាប់លេខាធិការគណៈកម្មការ សមាជិក សមាជិកាព្រឹទ្ធសភា ។

២. ឯកសណ្ឋានមាន២ប្រភេទ ៖

-ឯកសណ្ឋានផ្លូវការ

-ឯកសណ្ឋានប្រពៃណីជាតិ ។

ប្រធានព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



អនុប្រធានព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ប្រធានគណៈកម្មការព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



អនុប្រធានគណៈកម្មការព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



លេខាធិការគណៈកម្មការ និងសមាជិក សមាជិការព្រឹទ្ធសភា

សក្តិចុងកអាវ




សក្តិស្មា




សក្តិចុងដៃអាវ



សំលៀកបំពាក់ផ្នែកការ



សំលៀកបំពាក់ប្រពៃណីជាតិ



កន្លាស់សញ្ញាព្រឹទ្ធសភា



<u>មាតិកា</u>

សេចក្តីផ្តើម ១

សាវតារ ១

I **លទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី១ (១៩៩៩-២០០៦)** ២

១. មុខងារនីតិកម្ម ២

១-១ សម័យប្រជុំព្រឹទ្ធសភា ៣

១-២ សកម្មភាពគណៈកម្មាធិការអចិន្ត្រៃយ៍ ៣

១-៣ សកម្មភាពថ្នាក់ដឹកនាំ ៣

១-៤ សកម្មភាពគណៈកម្មការជំនាញទាំង៩ ៣

១-៥ គណៈកម្មការពិសេស ៤

១-៦ សកម្មភាពរបស់សមាជិក សមាជិកាព្រឹទ្ធសភា ៤

២. ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ៤

២-១ ការងារទំនាក់ទំនងសាធារណៈ ៤

២-២ កិច្ចសហប្រតិបត្តិការអន្តរជាតិ ៤

២-៣ លទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ៥

៣. លទ្ធផលការងារអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (១៩៩៩-២០០៦) ៥

៣-១ ការកកើត ៥

៣-២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ៥

ក. ១៩៩៩-២០០៥ ៥

ខ. ២០០៥ ៦

៣-៣ ការគ្រប់គ្រងមន្ត្រីរាជការ ៨

ក. ចំនួនមន្ត្រីរាជការ ៨

ខ. កម្រិតវប្បធម៌ ៩

គ. ការបណ្តុះបណ្តាល ៩

៣-៤ ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ៩

II **លទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី២ (២០០៦-២០១២)** ១០
១. មុខងារតំណាង ១០
២. មុខងារនីតិកម្ម ១៤
២-១ សម័យប្រជុំព្រឹទ្ធសភា ១៥
២-២ សកម្មភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ១៦
២-៣ តារាងសង្ខេបស្តីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ ១៦
២-៤ សកម្មភាពរបស់គណៈកម្មការជំនាញទាំង៩ ១៦
២-៥ គណៈកម្មការពិសេសរបស់ព្រឹទ្ធសភា ១៧
៣. មុខងារត្រួតពិនិត្យ ១៧
៤. មុខងារព័ត៌មាន ១៨
៥. ការងារទំនាក់ទំនងសាធារណៈ និងទំនាក់ទំនងអន្តរជាតិ ១៨
រូបភាពស្តីពីសកម្មភាពថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ឆ្នាំ២០០៦-២០១២ ២១
៦. លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ៥៣
ក. គោលការណ៍គ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ៥៣
ខ. ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេស ៦២
ខ.១ ការបណ្តុះបណ្តាលនៅក្នុងប្រទេស ៦២
ខ.២ ការបណ្តុះបណ្តាលនៅក្រៅប្រទេស ៦៣
គ. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថាប័នព្រឹទ្ធសភា ៦៣
រូបភាពស្តីពីសកម្មភាពរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឆ្នាំ២០០៦-២០១២ ៦៥
៧. ការប្រឈម ៧៩
៨. ចក្ខុវិស័យ ៧៩
ក. ចក្ខុវិស័យរបស់ព្រឹទ្ធសភា ៧៩
ខ. ចក្ខុវិស័យរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ៧៩
៩. សេចក្តីសន្និដ្ឋាន ៨០
តារាងឧបសម្ព័ន្ធស្តីពីតួលេខនៃកិច្ចសហប្រតិបត្តិការអន្តរជាតិព្រឹទ្ធសភា នីតិកាលទី២ ៨១

សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការបែងចែកអំណាច៣ដាច់ពីគ្នាគឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

ព្រឹទ្ធសភា ជាស្ថាប័នជាតិជាន់ខ្ពស់ ដែលមានអំណាចនីតិប្បញ្ញត្តិ បានចាប់បដិសន្ធិ នាថ្ងៃ ទី២៥ ខែមីនា ឆ្នាំ១៩៩៩។ ព្រឹទ្ធសភា បានរួមចំណែកដល់ការពង្រឹងពង្រីកសន្តិភាព ស្ថិរភាពនយោបាយ ការបង្រួបបង្រួមផ្សះផ្សាជាតិ ការកសាង និងអភិវឌ្ឍន៍ជាតិ ព្រមទាំងបុព្វហេតុនៃការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោកនាយុគសម័យនៃសកលភាវូបនីយកម្ម។

ព្រឹទ្ធសភាបានចូលរួមឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ចំពោះមុខ និងយូរអង្វែងរបស់ប្រទេសជាតិ ដែលរាជរដ្ឋាភិបាលបាននិងកំពុងដំរុញការកែទម្រង់លើគ្រប់វិស័យនៃការគ្រប់គ្រងរដ្ឋ គ្រប់គ្រងសង្គម គ្រប់គ្រងសេដ្ឋកិច្ចឱ្យមានសន្ទុះរីកចម្រើនទៅមុខតាមមាគ៌ានៃការអភិវឌ្ឍ ក្នុងតម្លាភាព យុត្តិធម៌ ស្អាតស្អំ និងទទួលខុសត្រូវ។ គុណភាព និងប្រសិទ្ធភាពនៃប្បាប់រដ្ឋ ព្រមទាំងភាពជាតំណាងឱ្យផលប្រយោជន៍ប្រជាជាតិទាំងមូល និងក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេសជាអាទិភាពចម្បងមួយ ដែលព្រឹទ្ធសភាត្រូវតម្រង់ទិស សម្រិតសម្រាំងនៅក្នុងសកម្មភាពការងារជាក់ស្តែងរបស់ខ្លួន ជាពិសេសក្នុងមុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ។

ម្យ៉ាងទៀត ព្រឹទ្ធសភាបានរួមចំណែកជាកូនជញ្ជីងមួយ ដើម្បីផ្តល់យោបល់ តម្រង់ទិស និងជួយពង្រឹងការដឹកនាំ គ្រប់គ្រងរដ្ឋ ក្នុងដំណើរឆ្ពោះទៅកាន់នីតិរដ្ឋ និងអភិបាលកិច្ចល្អ។ ការដើរតួនាទីជាយន្តការសម្របសម្រួលរវាងរដ្ឋសភា និងរាជរដ្ឋាភិបាល មានទិសដៅធ្វើឱ្យអំណាចរដ្ឋមានតុល្យភាព និងប្រព្រឹត្តទៅដោយល្អប្រសើរ សំដៅការពារមូលដ្ឋានគ្រឹះនៃរដ្ឋធម្មនុញ្ញ គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងធានាអះអាងជូនប្រជាពលរដ្ឋគ្រប់រូប គ្រប់មជ្ឈដ្ឋានគ្រប់ការគោរពសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពផ្សេងៗទៀត ដែលញុំាងឱ្យបរិយាកាសសង្គមជាតិបន្តសុខដុមរមនាយូរអង្វែង និងដើរឆ្ពោះលើផ្លូវអភិវឌ្ឍជាតិប្រកបដោយចីរភាព។

សមិទ្ធផលព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២)នេះ ឆ្លុះបញ្ចាំងនូវកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតរបស់ព្រឹទ្ធសភា ដើម្បីឱ្យការបំពេញមុខងារទាំង៣របស់ខ្លួនប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ដែលតំណាងឱ្យផលប្រយោជន៍ឃុំ-សង្កាត់ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងមូល។ សមិទ្ធផលនីតិកាលទី២នេះ នឹងរៀបរាប់សង្ខេបអំពីលទ្ធផលការងារជាប្រើន ដែលព្រឹទ្ធសភានីតិកាលទី១ (១៩៩៩-២០០៦) សម្រេចបានក្នុងរយៈពេលដែលទើបបង្កើតឡើងដោយជម្នះនូវរាល់ឧបសគ្គតូច-ធំផងទាំងពួង និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន ដែលជាសេនាធិការរបស់ព្រឹទ្ធសភា។

សាវតារ

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតបន្ទាប់ពីកិច្ចប្រជុំរវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណបក្សនយោបាយធំៗទាំងពីរ នៅថ្ងៃទី១២ និងទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** នៅព្រះបរមរាជវាំង ក្នុងគោលបំណងបញ្ចប់វិបត្តិនយោបាយ លើកកម្ពស់ការបង្រួបបង្រួមផ្សះផ្សាជាតិ និងពង្រឹងស្ថិរភាពនយោបាយ។

ការបង្កើតស្ថាប័នព្រឹទ្ធសភានេះ គឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រកម្ពុជា បានបង្ហាញឱ្យឃើញនូវពន្លឺថ្មីមួយសម្រាប់អនាគតនៃប្រទេសកម្ពុជា តាមរយៈការមានស្ថិរភាពផ្នែកនយោបាយ ព្រមទាំងបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់ ក្នុងការកសាងនីតិរដ្ឋដូចអារ្យប្រទេសនានា ។ ដោយអនុលោមទៅតាមវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រឹទ្ធសភានីតិកាលទី១ បើកសម័យប្រជុំដំបូងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។ ក្នុងនីតិកាលទី១នេះ សមាជិកព្រឹទ្ធសភាត្រូវបានតែងតាំងដោយព្រះមហាក្សត្រតាមសំណើរបស់ប្រធានព្រឹទ្ធសភា និងរដ្ឋសភាក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។ ព្រឹទ្ធសភាមានសមាជិកចំនួន ៦១រូប ដែលក្នុងនោះមានសមាជិកមកពីគណបក្សប្រជាជនកម្ពុជាចំនួន ៣១រូប គណបក្សហ៊្វុនស៊ិនប៉ិចចំនួន ២១រូប គណបក្សសម រង្ស៊ីចំនួន ៧រូប តំណាងព្រះមហាក្សត្រចំនួន ២រូប។ នីតិកាលទី១របស់ព្រឹទ្ធសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវបានប្រកាសបន្តនីតិកាលពីរដង ម្តងមួយឆ្នាំ ចាប់ពីឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០០៦ ជារយៈកាលនៃដំណើរការនីតិកាលទី១របស់ព្រឹទ្ធសភា។

ព្រឹទ្ធសភានីតិកាលទី២ ប្រសូតឡើងតាមការបោះឆ្នោតអសកល មិនចំពោះតាមវិធីបោះឆ្នោតជាសម្ងាត់នាថ្ងៃទី២២ ខែមករា ឆ្នាំ២០០៦ ដោយមានអ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌភូមិភាគទាំង ៨ នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនីតិកាលទី២នេះ ព្រឹទ្ធសភាមានសមាជិកចំនួន ៦១រូប ក្នុងនោះមាន ៥៧រូប ជ្រើសតាំងដោយការបោះឆ្នោតដែលមានសមាជិកគណបក្សប្រជាជនកម្ពុជាចំនួន ៤៥រូប គណបក្សហ៊្វុនស៊ិនប៉ិចចំនួន ១០រូប គណបក្សសម រង្ស៊ីចំនួន ០២រូប ។ ក្រៅពីនេះមានសមាជិកព្រឹទ្ធសភាចំនួន ២រូប ជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប និងសមាជិកព្រឹទ្ធសភាចំនួន ២រូបទៀត តែងតាំងដោយព្រះមហាក្សត្រ។ ព្រឹទ្ធសភា នីតិកាលទី២ បើកសម័យប្រជុំដំបូងរបស់ខ្លួន នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ហើយមានអាណត្តិកំណត់ ៦ឆ្នាំ។

I លទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី១ (១៩៩៩-២០០៦)

ក្នុងនីតិកាលទី១របស់ខ្លួន ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលយ៉ាងត្រចះត្រចង់ និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការកសាងប្រព័ន្ធច្បាប់ជាធរមានរបស់រដ្ឋ និងកសាងនូវមូលដ្ឋានគ្រឹះជាសក្តានុពលផ្ទាល់ខ្លួនសម្រាប់ការពង្រឹងលក្ខន្តិក: និងអត្តសញ្ញាណជាស្ថាប័នជាន់ខ្ពស់ទទួលខុសត្រូវចំពោះជាតិ និងប្រជាពលរដ្ឋទាំងមូល ។

ក្នុងប្រវត្តិសាស្ត្ររបស់ស្ថាប័នព្រឹទ្ធសភា សមាជិក សមាជិកា នីតិកាលទី១ គឺជាអ្នកឱតខំឈានមុខ និងជាអ្នកត្រួសត្រាយផ្លូវដ៏សំខាន់ ដែលធ្វើឲ្យស្ថាប័ននេះបោះមួយជំហានទៅមុខដោយមានមូលដ្ឋានគ្រឹះរឹងមាំ។ ម្យ៉ាងវិញទៀត ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងដោយមានកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រពៃពីគ្រប់ស្ថាប័ន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍អន្តរជាតិនានា ព្រឹទ្ធសភានីតិកាលទី១ ទទួលបានជោគជ័យគួរឲ្យកត់សម្គាល់ ។


១-មុខងារនីតិកម្ម

ព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់លើអត្ថបទច្បាប់ចំនួន ១២៨ច្បាប់ ក្នុងចំណោមអត្ថបទច្បាប់

ចំនួន១៣៧ ដែលរដ្ឋសភាបញ្ជូនមក ។ ក្នុងចំណោមអត្ថបទច្បាប់ចំនួន ១២៨ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ មានអត្ថបទច្បាប់ចំនួន២ ដែលព្រឹទ្ធសភា បានស្នើសុំឱ្យរដ្ឋសភាធ្វើការកែសម្រួលឡើងវិញ និងអត្ថបទច្បាប់មួយទៀត ព្រឹទ្ធសភាបានសម្រេចលើកចោលពុំយកមកពិចារណា។

១-១ សម័យប្រជុំព្រឹទ្ធសភា

ព្រឹទ្ធសភា នីតិកាលទី១បានដំណើរការសម័យប្រជុំ ចំនួន១០លើក ប្រជុំចំនួន ៩៤លើក និងប្រជុំវិសាមញ្ញ ចំនួន០២លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើអត្ថបទច្បាប់ សរុបចំនួន ១២៨ ។



១-២ សកម្មភាពគណៈកម្មាធិការអចិន្ត្រៃយ៍

បានប្រជុំចំនួន ៩៦លើក ដើម្បីរៀបចំរបៀបវារៈ កំណត់កាលបរិច្ឆេទនៃការកោះប្រជុំ និងជ្រើសរើសលេខាធិការសម្រាប់អង្គប្រជុំនីមួយៗ ព្រមទាំងពិនិត្យ និងសម្រេចលើការងារផ្ទៃក្នុងរបស់ព្រឹទ្ធសភា មានជាអាទិ៍ ការអនុម័តសេចក្តីសម្រេចស្តីពីតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការជំនាញទាំង៩ គម្រោងថវិកាប្រចាំឆ្នាំ សេចក្តីសម្រេចបង្កើតក្រុមមិត្តភាពទ្វេភាគី និងពហុភាគីរវាងព្រឹទ្ធសភាកម្ពុជា និងសភានៃប្រទេសនានា ក្រុមទទួលបន្ទុកការងារសហភាពអន្តរសភា (IPU) ក្រុមទទួលបន្ទុកការងារអន្តរសភាអាស៊ាន (AIPO) ។ល។

១-៣ សកម្មភាពថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំព្រឹទ្ធសភាទាំង៣រូប បានដឹកនាំអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន៩៦លើក ដឹកនាំប្រជុំព្រឹទ្ធសភា ចំនួន៩៦លើក និងបានទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន១៤លើក ។

១-៤ សកម្មភាពគណៈកម្មការជំនាញទាំង៩

ក្នុងនីតិកាលទី១នេះ គណៈកម្មការជំនាញទាំង៩ របស់ព្រឹទ្ធសភាបានពិនិត្យអត្ថបទច្បាប់ចំនួន១២៨ច្បាប់ ចុះទៅតាមបណ្តាមូលដ្ឋាន ដើម្បីសួរសុខទុក្ខ និងស្វែងយល់ពីកង្វល់របស់ប្រជាពលរដ្ឋបានចំនួន ៣.៦៣៧ លើក និងបានបញ្ជូនពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ចចំនួន ១.៨៨០ ករណី ។

១-៥ គណៈកម្មការពិសេស

ព្រឹទ្ធសភាបានបង្កើតគណៈកម្មការពិសេសចំនួន ០៣ ទទួលបន្ទុក ៖

១-រៀបចំសេចក្តីស្នើ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

២-រៀបចំសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

៣-ពិនិត្យ និងសិក្សាអំពីការស្នើផ្តល់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកាព្រឹទ្ធសភា នៅពេលបញ្ចប់នីតិកាលទី១ ។

១-៦ សកម្មភាពរបស់សមាជិក សមាជិកាព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានចូលរួមយ៉ាងសកម្មក្នុងការពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ និងបានចូលរួមដោះស្រាយបញ្ហាជាច្រើនជូនប្រជាពលរដ្ឋ ដើម្បីជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមរយៈការងារសង្គមកិច្ច ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន។ល។ សកម្មភាពរបស់សមាជិក សមាជិកាព្រឹទ្ធសភា បានរួមចំណែកបម្រើដល់ផលប្រយោជន៍ជាតិ ប្រជាជន និងដល់ការកសាងកម្ពុជាជានីតិរដ្ឋ និងការអភិវឌ្ឍរបស់ប្រទេសជាតិ ។

២-ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ

២-១ ការងារទំនាក់ទំនងសាធារណៈ

ព្រឹទ្ធសភាចាត់ទុកថាទំនាក់ទំនងសាធារណៈ ជាកិច្ចការយ៉ាងសំខាន់ក្នុងចំណោមកិច្ចការសំខាន់ៗឯទៀតរបស់ខ្លួន ។ ទំនាក់ទំនងសាធារណៈជាស្ពានចម្លងពីស្ថាប័នព្រឹទ្ធសភា ទៅប្រជាពលរដ្ឋទូទាំងប្រទេស ។

ក្នុងនីតិកាលទី១នេះ តាមរយៈទំនាក់ទំនងសាធារណៈ ព្រឹទ្ធសភាបានប្រើប្រាស់មធ្យោបាយប្រើនរូបភាពដូចជា ៖

-ការជួបប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន ការជួបផ្លាស់ប្តូរយោបល់ជាមួយនឹងអង្គការសង្គមស៊ីវិល អាជ្ញាធរគ្រប់ជាន់ថ្នាក់ តាមរយៈការប្រជុំឯកបទពិសោធន៍ ឬសិក្ខាសាលា

-ការទទួលជួបជាមួយនឹងប្រជាពលរដ្ឋដែលមកសុំពិគ្រោះយោបល់លើបញ្ហាច្បាប់ ឬមកដាក់ពាក្យបណ្តឹងផ្សេងៗនៅព្រឹទ្ធសភា

-បើកឲ្យប្រជាពលរដ្ឋ សិស្ស និស្សិត ចូលមកទស្សនា និងទស្សនកិច្ចសិក្សានៅព្រឹទ្ធសភា ដើម្បីស្វែងយល់អំពីព្រឹទ្ធសភា និងធ្វើការសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យព្រឹទ្ធសភា ។ ជាក់ស្តែងក្នុងនីតិកាលទី១ ព្រឹទ្ធសភា មានសិស្ស និស្សិត ចំនួន ៥០.៧០៤នាក់ ចូលមកធ្វើការស្រាវជ្រាវក្នុងបណ្ណាល័យ ។

-ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ មានវិទ្យុ ទូរទស្សន៍ ព្រឹត្តិបត្រប្រចាំខែរបស់ព្រឹទ្ធសភា តាមគេហទំព័រ (Website) របស់ព្រឹទ្ធសភាអំពីសកម្មភាពផ្សេងៗរបស់ព្រឹទ្ធសភា និងច្បាប់សំខាន់ៗ ។ល។

២-២ កិច្ចសហប្រតិបត្តិការអន្តរជាតិ

ព្រឹទ្ធសភាបានពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយនឹងសភានៃប្រទេសជាមិត្ត តាមរយៈការបង្កើតក្រុមមិត្តភាពជាមួយនឹងសភានានា និងការចូលជាសមាជិកភាពក្នុង IPU, AIPA, APF ។ល។ និងភាពជាដៃគូយូរអង្វែងជាមួយនឹងអង្គការ UNDP, KAF និង CIDA តាមរយៈគម្រោងគាំទ្រនីតិប្បញ្ញត្តិ កម្ពុជា-

កាណាដា (CCLSP) មូលនិធិអាស៊ី និងដៃគូអន្តរជាតិផ្សេងទៀត ។ ជាពិសេស រដ្ឋាភិបាលចិន ជប៉ុន វៀតណាម ព្រឹទ្ធសភាបារាំង កាណាដា អូស្ត្រាលី បានចូលរួមចំណែកយ៉ាងសកម្មជួយដល់ព្រឹទ្ធសភាកម្ពុជា។

២-៣ លទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ

ព្រឹទ្ធសភាបានទទួលជំនួយជាបន្តបន្ទាប់ពីរដ្ឋាភិបាល និងសភានៃបណ្តាប្រទេសជាមិត្តសម្រាប់ការស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធ និងសម្រាប់អភិវឌ្ឍស្ថាប័នមានទឹកប្រាក់សរុប ៤.០៣២.៦៦២ដុល្លារអាមេរិក ក្នុងនោះមាន ៖

-សាធារណរដ្ឋប្រជាមានិតចិន ចំនួន **៣.០៧៩.៤៩៤** USD
-ជប៉ុន ចំនួន **៨៥៣.១៦៨** USD
-វៀតណាម ចំនួន **៥៥.000** USD
-បារាំង ចំនួន **២៥.000** USD
-ប្រ៊ុយណេដារូសាឡឹម ចំនួន **២0.000** USD
-សាធារណរដ្ឋកូរ៉េ រថយន្ត ចំនួន ០១គ្រឿង និងទូឯកសារចំនួន ០៥
-ឥណ្ឌូនេស៊ី ផ្តល់គ្រឿងសង្ហារឹម នៅក្នុងបន្ទប់ទទួលភ្ញៀវនៃអគារក្រហម ។

ការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ៖

ព្រឹទ្ធសភា បានបញ្ជូនគណៈប្រតិភូជាច្រើនក្រុមទៅធ្វើទស្សនកិច្ចជាផ្លូវការ ទស្សនកិច្ចសិក្សាដកបទពិសោធន៍ការងារសភា ចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា មានចំនួន៨២គណៈប្រតិភូ និងបានទទួលគណៈប្រតិភូបរទេសមកបំពេញទស្សនកិច្ច និងចូលរួមប្រជុំនៅព្រះរាជាណាចក្រកម្ពុជា មានចំនួន ២៤៥ លើក ។ ជាពិសេសក៏មានការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ដើម្បីរឹតចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការល្អលើគ្រប់វិស័យរវាងស្ថាប័នសភា និងប្រជាជននៃប្រទេសនានាឲ្យកាន់តែជិតស្និទ្ធ និងខ្លាំងក្លាថែមទៀត ។

ជាការកត់សម្គាល់នៅក្នុងនីតិកាលទី១ ព្រឹទ្ធសភាបានទទួលគណៈប្រតិភូជាន់ខ្ពស់សភានៃបណ្តាប្រទេសជាមិត្តមានដូចជាអាទិ៍ គណៈប្រតិភូក្រុមប្រឹក្សានយោបាយប្រជាជនចិន គណៈប្រតិភូព្រឹទ្ធសភាបារាំង គណៈប្រតិភូព្រឹទ្ធសភាបែលហ្ស៊ិក គណៈប្រតិភូព្រឹទ្ធសភាកាណាដា និងគណៈប្រតិភូសភាអូស្ត្រាលី ។


៣-លទ្ធផលការងារអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (១៩៩៩-២00៦)

៣-១ ការកើត

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវបានបង្កើតដោយបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ឆ្នាំ១៩៩៩ ជំពូកទី៤ ប្រការ១៥ "ព្រឹទ្ធសភាមានអគ្គលេខាធិការដ្ឋានមួយសម្រាប់ទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា របស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងរបស់គណៈកម្មការនានា... ។"

៣-២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ក-១៩៩៩-២00៥ : អគ្គលេខាធិការដ្ឋានមាន ៧អង្គភាពចំណុះគឺ (១)អគ្គាធិការដ្ឋាន (២)ក្រុមប្រឹក្សាច្បាប់ (៣)នាយកដ្ឋានរដ្ឋបាល (៤)នាយកដ្ឋានហិរញ្ញវត្ថុ (៥)នាយកដ្ឋានឥតិវិធី (៦)ការិយាល័យបច្ចេកទេស និង(៧)ការិយាល័យពិធីការ ។



ខ-ឆ្នាំ២០០៥ : រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានត្រូវបានពង្រីកដល់ ១២អង្គភាពចំណុះ គឺ (១)លេខាធិការដ្ឋាន (២)អគ្គាធិការដ្ឋាន (៣)នាយកដ្ឋានស្រាវជ្រាវច្បាប់ (៤)នាយកដ្ឋានរដ្ឋបាល (៥)នាយកដ្ឋានហិរញ្ញវត្ថុ (៦)នាយកដ្ឋាននីតិវិធី (៧)នាយកដ្ឋានជំនួយការគណៈកម្មការ (៨)នាយកដ្ឋានធនធានមនុស្ស (៩)នាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ (១០)នាយកដ្ឋានព័ត៌មាន (១១)នាយកដ្ឋានភូមិភាគ និងសមូហភាពដែនដី និង(១២)បណ្ណាល័យ ។

ព្រឹទ្ធសភា
ខុទ្ទកាល័យ
អគ្គាធិការដ្ឋាន
អគ្គលេខាធិការដ្ឋាន
លេខាធិការដ្ឋាន
ន.ពិធីការ-ចំណាត់ថ្នាក់ថ្នាក់ទំនងអន្តរជាតិ
ក-របៀប
ក-ពិធីការ
ក-ទំនាក់ទំនងអន្តរជាតិ
ក-បកប្រែ
ន.រដ្ឋបាល
ក-រដ្ឋបាលទូទៅ
ក-សេវាកម្ម
ក-សន្តិសុខ និងដឹកជញ្ជូន
ក-បច្ចេកទេស
ន.ហិរញ្ញវត្ថុ
ក-របៀប
ក-គណនេយ្យ
ក-ផ្គត់ផ្គង់ និងសំណង់
ក-ហិរញ្ញកិច្ច និងផែនការថវិកា
ក-សំណង់
ន.ធនធានមនុស្ស
ក-របៀប
ក-បុគ្គលិក
ក-អភិវឌ្ឍធនធានមនុស្ស
ក-បៀវត្ស និងពលកម្ម
ន.នីតិវិធី
ក-របៀប
ក-នីតិវិធី
ក-កំណត់ហេតុសង្ខេប
ក-កំណត់ហេតុពិស្តារ (ហង្សា)
ន.ជំនួយការគណៈកម្មការនានា
ក-របៀប
ក-ទី១ (គ-១,៨,៩)
ក-ទី២ (គ-៤,៥,៦)
ក-ទី៣ (គ-២,៣,៧)
ន.ស្រាវជ្រាវច្បាប់
ក-របៀប
ក-ច្បាប់សាធារណៈ
ក-ច្បាប់ឯកជន
ក-ច្បាប់អន្តរជាតិ
ក-ច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី
បណ្ណាល័យ
ក-របៀប
ក-គ្រប់គ្រងសៀវភៅ
ក-ព័ត៌មានវិទ្យា
ក-បណ្ណសារ
ន.ព័ត៌មាន
ក-របៀប
ក-ព័ត៌មាន
ក-បោះពុម្ព
ក-សរុប
ក-ផ្សព្វផ្សាយ
ន.អូមិតាគ និងសមូហភាពដែនដី
ក-របៀប
ក-ទី១
ក-ទី២
ក-ទី៣
ក-ទី៤

ការកែសម្រួលរចនាសម្ព័ន្ធ (១៩៩៩-២០០៥) និងឆ្នាំ២០០៥ ជាការឆ្លុះបញ្ចាំងអំពីភាពរីកចម្រើននៃការងារពីមួយថ្ងៃទៅមួយថ្ងៃរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងការផ្តល់នូវសេវាជូនព្រឹទ្ធសភាឱ្យកាន់តែទូលំទូលាយប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ដើម្បីឱ្យព្រឹទ្ធសភាបំពេញការងាររបស់ខ្លួនកាន់តែប្រសើរឡើងថែមទៀតលើភាពជាតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេស ។

តួនាទី និងភារកិច្ចរបស់អង្គភាពនីមួយៗត្រូវបានរៀបចំឡើង ហើយអាចឆ្លើយតបបានទៅនឹងតម្រូវការនាពេលអនាគតរបស់ព្រឹទ្ធសភា ។


៣-៣ ការគ្រប់គ្រងមន្ត្រីរាជការ

នៅពេលចាប់ដំណើរការដំបូងនាឆ្នាំ១៩៩៩ ការគ្រប់គ្រងផ្អែកតែលើបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន ដែលផ្តោតតែទៅលើវិន័យការងារតែប៉ុណ្ណោះ ។ ក្នុងស្ថានភាពនេះ អគ្គលេខាធិការដ្ឋានបានប្រឈមនឹងបញ្ហាជាច្រើនដែលទាក់ទងដល់ភាពអព្យាក្រឹតនៃមន្ត្រីរាជការ ភាពមិនច្បាស់លាស់នៃក្របខ័ណ្ឌ សិទ្ធិ ផលប្រយោជន៍ និងកាតព្វកិច្ចរបស់មន្ត្រីរាជការម្នាក់ៗ ។ រហូតមកដល់ដើមឆ្នាំ២០០៣ បញ្ហាទាំងប៉ុន្មាននេះត្រូវបានដោះស្រាយ ដោយច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ បន្ទាប់ពីការធ្វើសមាហរណកម្មមន្ត្រីបុគ្គលិកចូលក្នុងក្របខ័ណ្ឌដែលមានកំណត់ក្នុងច្បាប់ និងការរៀបចំប្រព័ន្ធប្រាក់បៀវត្សថ្មីដែលមានលក្ខណៈប្រសើរជាងមុន ។

ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានបានដំណើរការតាក់តែងគោលនយោបាយគ្រប់គ្រងធនធានមនុស្សចំនួន៨ ដែលទាក់ទងនឹងការជ្រើសរើសអ្នករាជការឱ្យចូលធ្វើការ ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ការពិពណ៌នាការងារ ការបណ្តុះបណ្តាលធនធានមនុស្ស និងការអភិវឌ្ឍធនធានមនុស្ស ការជំរុញ និងលើកទឹកចិត្ត ការងារស្ត្រី ការតែងតាំងឱ្យកាន់មុខតំណែងគ្រប់គ្រង និងរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ។ គោលនយោបាយទាំងនេះត្រូវបានដាក់ឱ្យអនុវត្តព្រមគ្នា នៅចុងឆ្នាំ២០០៥ ជាមួយនឹងបទបញ្ជាផ្ទៃក្នុងថ្មីនៃអគ្គលេខាធិការដ្ឋាន ។


ក-ចំនួនមន្ត្រីរាជការ

ឆ្នាំ	១៩៩៩	២000	២00១	២00២	២00៣	២00៤	២00៥
ចំនួន	១៩0-២១៩	២៥៧	២៩២	៣0២	៣00	២៧៧	២៨៩



ខ-កម្រិតវប្បធម៌

ឆ្នាំ	១៩៩៩	២០០៥
បំនួនមន្ត្រីបុគ្គលិកសរុប	២១៩ នាក់	២៨៩ នាក់
ក្រោមទុតិយភូមិ	៦០ នាក់	១០១ នាក់
ទុតិយភូមិ	១០៦ នាក់	៧៦ នាក់
បរិញ្ញាបត្រ	៥០ នាក់	៩៧ នាក់
អនុបណ្ឌិត	៣ នាក់	១៥ នាក់



គ-ការបណ្តុះបណ្តាល

១-ក្នុងប្រទេស : ២.៦២២នាក់

២-ក្រៅប្រទេស : ៤៤នាក់

សរុប : ២.៦៦៦ នាក់ ។

លទ្ធផលនៃការបណ្តុះបណ្តាលខាងលើនេះ បានមកដោយកិច្ចសហប្រតិបត្តិការរយៈពេលវែងជាមួយនឹងសហភាពអន្តរសភា កម្មវិធីសហប្រជាជាតិសម្រាប់ការអភិវឌ្ឍន៍ គម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា មូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ ព្រឹទ្ធសភាបារាំង ។ល។

៣-៤ ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ

ដោយមានការជួយឧបត្ថម្ភពីដៃគូសហប្រតិបត្តិការ ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ដែលមាន៥គោលដៅត្រូវបានកសាងឡើង និងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០០៣មក ។ គោលដៅទាំង៥នេះសំដៅដល់ការពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងជំនាញដល់បុគ្គលិក ការពង្រឹងរចនាសម្ព័ន្ធរួម ប្រព័ន្ធគោលនយោបាយ និងនីតិវិធីការងារព័ត៌មាន ការងារស្រាវជ្រាវ និងការងារឯកសារ ។

លើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រនេះ អង្គភាពនីមួយៗបានរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្ររបស់ខ្លួនដែលមានចក្ខុវិស័យ គោលដៅ និងសកម្មភាពស្របតាមតួនាទី និងភារកិច្ចរៀងៗខ្លួន ។

នីតិកាលទី១ ជាដំណាក់កាលកំណែ កន្លងរបស់ព្រឹទ្ធសភា ។ ក្នុងដំណាក់កាលនេះ អគ្គលេខាធិការ

ដ្ឋានព្រឹទ្ធសភា បានឆ្លងកាត់នូវវិញ្ញាសានៃការសាកល្បងយ៉ាងតឹងតែង និងខិតខំពុះពារឧបសគ្គ និងការលំបាកតូចធំទាំងឡាយ រហូតសម្រេចបានផ្លែផ្កាលទ្ធផលធំៗនាចុងនីតិកាល ។ ស្នាដៃដែលគួរឱ្យកត់សម្គាល់ គឺការបណ្តុះបណ្តាលជំនាញ ការកែលម្អរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន ការកសាងប្រព័ន្ធគោលនយោបាយគ្រប់គ្រងធនធានមនុស្ស នីតិវិធីធ្វើការងារ ការកែលំអ និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់មធ្យោបាយសម្រាប់បំពេញការងារ ។ ការងារសហប្រតិបត្តិការអន្តរជាតិទទួលបានជោគជ័យយ៉ាងធំធេង ។ សមិទ្ធផលនេះជាគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍគ្រប់វិស័យឈានទៅសម្រេចនូវចក្ខុវិស័យ និងគោលដៅទាំងអស់នៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់ស្ថាប័នព្រឹទ្ធសភា ។

II លទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី២ (២០០៦-២០១២)

ព្រឹទ្ធសភាមានមុខងារសំខាន់ៗចំនួន ៣ គឺមុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ ។ ដោយឡែកគណៈកម្មការជំនាញទាំង ៩ មានមុខងារនីតិកម្ម មុខងារត្រួតពិនិត្យ និងមុខងារព័ត៌មាន ។

ក្នុងនីតិកាលទី២នេះ ព្រឹទ្ធសភាបានខិតខំបំពេញការងារយ៉ាងសកម្មដោយទទួលបានផ្លែផ្កាលទ្ធផលដូចតទៅ ៖

១-មុខងារតំណាង

ក្នុងមុខងារតំណាង ព្រឹទ្ធសភាបានបើកវេទិកាថ្នាក់ជាតិចំនួន ១លើក វេទិកាភូមិភាគចំនួន ១២លើក និងវេទិកាសមាជិកាចំនួន ០៥លើក ក្នុងភូមិភាគទាំង៨ ដែលមានសមាសភាពចូលរួមសរុបចំនួន ៤.៥៨៩នាក់ ក្នុងនោះមានតំណាងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន ២.៤៤០នាក់ ។ ក្រៅពីនេះសមាជិក សមាជិកាព្រឹទ្ធសភា បានបើកសិក្ខាសាលា កិច្ចពិភាក្សា និងពិធីសំណេះសំណាលតាមភូមិភាគ និងតាមរាជធានី ខេត្ត បានចំនួន ១៧លើក ដែលមានសមាសភាពចូលរួមសរុបចំនួន ៣.៥៨៨នាក់ ក្នុងនោះមានសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មការភូមិចំនួន ២.៣៨៣នាក់ ។

វេទិកាថ្នាក់ជាតិ និងភូមិភាគទាំង ១៣ លើក មានដូចខាងក្រោម ៖

-ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិភាគទី៤ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន ១៦០នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ៦៦នាក់ ។

-ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិភាគទី៧ ប្រព្រឹត្តទៅនៅសណ្ឋាគារ Grand Hotel ខេត្តកោះកុង កាលពីថ្ងៃទី ២៤-២៥ ខែកញ្ញា ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន ២៤៧នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ៥៥នាក់ ។

-ស្តីពី "សិទ្ធិមនុស្ស និងការគោរពច្បាប់នៅមូលដ្ឋាន វិមជ្ឈការ និងវិសហមជ្ឈការ និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិភាគទី១ ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងត្បូងព្រឹទ្ធសភា (វិមានរដ្ឋបំការមន) កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន ២០៩នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ៧៦នាក់ ។

-ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិ

ភាគទី៦ ប្រព្រឹត្តទៅនៅសាលប្រជុំឆ្នេរទន្លេ ខេត្តស្វាយរៀង កាលពីថ្ងៃទី២៤-២៥ ខែមករា ឆ្នាំ២០០៨ ដែលមានសមាសភាពចូលរួមសរុបចំនួន ៣៣៧នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ២១៦នាក់ ។

-ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិភាគទី៥ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តកំពត កាលពីថ្ងៃទី៣១ ខែមីនា ដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ ដែលមានសមាសភាពចូលរួមសរុបចំនួន ២៥៧នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ១៩០នាក់ ។

-ជ្ជាក់ជាតិស្តីពី "ការលើកកម្ពស់ផលប្រយោជន៍ឃុំ សង្កាត់ លើការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា" ប្រព្រឹត្តទៅក្នុងស្ថាប័នព្រឹទ្ធសភា (វិមានរដ្ឋចំការមន) កាលពីថ្ងៃទី០៣-០៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលមានសមាសភាពចូលរួមសរុបចំនួន ២០៤នាក់ ក្នុងនោះមានតំណាងប្រធាន អនុប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ចូលរួមចំនួន ៦៦ នាក់ ។

-ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិភាគទី៣ ប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តកណ្តាល កាលពីថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០០៨ ដែលមានសមាសភាពចូលរួមសរុបចំនួន ៣៤៧នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ១៩៣នាក់ ។

-ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិភាគទី២ ប្រព្រឹត្តទៅនៅសាលមហោស្រពព្រះសីហមុនី ខេត្តកំពង់ចាម កាលពីថ្ងៃទី០៣-០៤ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុបចំនួន ៣២៤នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ២២២នាក់ ។

-ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិភាគទី៨ ប្រព្រឹត្តទៅនៅសាលមហោស្រព ខេត្តក្រចេះ កាលពីថ្ងៃទី១៧-១៨ ខែមីនា ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុបចំនួន ១៨០នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ៨៨នាក់ ។

-ស្តីពី "ព្រឹទ្ធសភា និងផលប្រយោជន៍ក្រុមប្រឹក្សាឃុំ សង្កាត់" នៅភូមិភាគទី៥ ប្រព្រឹត្តទៅនៅសាលាគរុកោសល្យភូមិភាគខេត្តតាកែវ កាលពីថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ៣១២នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ២១៨នាក់ ។

-ស្តីពី "ព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ" នៅភូមិភាគទី៤ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តបាត់ដំបង កាលពីថ្ងៃទី១៧-១៨ ខែមីនា ឆ្នាំ២០១១ ដែលមានសមាសភាពចូលរួមចំនួន ២៦៤នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ១៧២នាក់។

-ស្តីពី "ព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ" នៅភូមិភាគទី១ ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងត្បូងព្រឹទ្ធសភា (វិមានរដ្ឋចំការមន) កាលពីថ្ងៃ

ទី០៥-០៦ ខែឧសភា ឆ្នាំ២០១១ ដែលមានសមាសភាពចូលរួមចំនួន ២៧០នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាសង្កាត់ចំនួន ១២០នាក់។

-ស្តីពី "ព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ" នៅភូមិភាគទី៨ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តកំពង់ធំ កាលពីថ្ងៃទី២២-២៣ ខែមិថុនា ឆ្នាំ ២០១១ ដែលមានសមាសភាពចូលរួមចំនួន ២៦១នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ចូលរួមចំនួន ១៣១នាក់។

វេទិកាសមាជិកាទាំង ៥ លើក មានប្រធានបទដូចខាងក្រោម ៖

-ស្តីពី "ការលើកកម្ពស់តួនាទី សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ" នៅភូមិភាគទី៧ ប្រព្រឹត្តទៅនៅសណ្ឋាគារ Grand Hotel ខេត្តកោះកុង កាលពីថ្ងៃទី១៩-២០ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុបចំនួន ១៦៧នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ៧១នាក់ ។

-ស្តីពី "ការលើកកម្ពស់យេនឌ័រ និងការបង្កើនភាពអង់អាចដល់សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់" នៅភូមិភាគទី៤ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តប៉ៃលិន កាលពីថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុបចំនួន ២១៥នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ១១៨នាក់ ។

-ស្តីពី "ការលើកកម្ពស់សមត្ថភាពសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីស្វែងយល់ និងអភិវឌ្ឍតាមតំបន់ទំនាបទន្លេមេគង្គ" នៅភូមិភាគទី២ ប្រព្រឹត្តទៅនៅសណ្ឋាគារ ៧ មករា ខេត្តកំពង់ចាម កាលពីថ្ងៃទី០១-០២ ខែមិថុនា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ២៦០នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងភូមិភាគចូលរួមចំនួន ១៦២នាក់ ។

-ស្តីពី "ការលើកកម្ពស់សមត្ថភាពសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការចូលរួមធ្វើសេចក្តីសម្រេចនៅថ្នាក់ក្រោមជាតិ" នៅភូមិភាគទី៣ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តកណ្តាល កាលពីថ្ងៃទី១៥-១៦ ខែកក្កដា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ២៨៥នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ១៧៤នាក់ ។

-ស្តីពី "ការលើកកម្ពស់សមត្ថភាពសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងការការពារសុវត្ថិភាពពលកម្មស្ត្រី និងកុមារ" នៅភូមិភាគទី៦ ប្រព្រឹត្តទៅនៅសាលប្រជុំឆ្នេរទន្លេ ក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីថ្ងៃទី២៨-២៩ ខែកញ្ញា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ២៩០នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងភូមិភាគចូលរួមចំនួន ១០២នាក់ ។

សិក្ខាសាលា និងកិច្ចពិភាក្សា សំណេះសំណាលរបស់សមាជិក សមាជិកាព្រឹទ្ធសភាទាំង១៧លើកមាន ៖

-កិច្ចពិភាក្សាស្តីពី "សារប្រយោជន៍ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា" នៅភូមិភាគទី៧ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន ៧៥នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ខេត្តកំពង់ឆ្នាំងចូលរួមចំនួន ៦០នាក់។

-កិច្ចពិភាក្សាស្តីពី "សារប្រយោជន៍ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា" នៅភូមិភាគទី៧ ប្រព្រឹត្តទៅនៅ

សាលប្រជុំសាលាខេត្តពោធិ៍សាត់ កាលពីល្ងាចថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន ៨១នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ខេត្តពោធិ៍សាត់ចូលរួមចំនួន ៦៦នាក់។

-ពិធីសំណេះសំណាលរវាងសមាជិកាព្រឹទ្ធសភា ជាមួយនឹងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ នៅភូមិភាគទី៨ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តកំពង់ធំ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន ១០៦នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ខេត្តកំពង់ធំចូលរួមចំនួន ៨០នាក់ ។

-ស្តីពី "ការលំបាក និងភាពងាយស្រួលរបស់សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់" នៅភូមិភាគទី៥ ប្រព្រឹត្តទៅនៅវត្តទន្លេបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុប ១៦៦នាក់ ក្នុងនោះមានសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន ១៥០នាក់ ។

-ពិធីសំណេះសំណាលរវាងសមាជិកាព្រឹទ្ធសភា ជាមួយនឹងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ នៅភូមិភាគទី៨ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តព្រះវិហារ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុបចំនួន ៩០នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ខេត្តព្រះវិហារ ចូលរួមចំនួន ៨៦នាក់ ។

-ស្តីពី "ការលើកកម្ពស់សមត្ថភាពរបស់សមាជិកាសង្កាត់ ក្នុងការចូលរួមចំណែកអភិវឌ្ឍមូលដ្ឋាន" ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងត្បូងព្រឹទ្ធសភា (វិមានរដ្ឋបំការមន) កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុបចំនួន ២២២នាក់ ក្នុងនោះមានសមាជិកាក្រុមប្រឹក្សាសង្កាត់ ចំនួន ១៦៣នាក់ ។

-ស្តីពី "ការពិគ្រោះយោបល់ជាមួយនឹងសាធារណជន និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ៣-៤-៥" នៅភូមិភាគទី១ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខណ្ឌទាំង៨ កាលពីថ្ងៃទី១៥-២៨ ខែមករា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ៤៧៨នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ចូលរួមចំនួន ៤៦២នាក់ ។

-ស្តីពី "ការលើកកម្ពស់សមត្ថភាពស្ត្រីថ្នាក់ក្រោមជាតិ ក្នុងការបញ្ជ្រាបយេនឌ័រ ផ្តោតទៅលើសុខុមាលភាពស្ត្រី និងកុមារ" នៅភូមិភាគទី៨ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តមណ្ឌលគីរី កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ១២១នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សា ឃុំ សង្កាត់ ចំនួន ២៣នាក់ ។

-ស្តីពី "សមភាពយេនឌ័រ សុខភាពទារកក្រោមអាយុ ០៥ឆ្នាំ និងសុខភាពមាតាសម្រាលបុត្រ" នៅភូមិភាគទី៧ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ១៦៧នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ចូលរួមចំនួន ៥៩នាក់ ។

-ស្តីពី "ការពិគ្រោះយោបល់ជាមួយនឹងសាធារណជន និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍៣-៥" នៅភូមិភាគទី១ ប្រព្រឹត្តទៅតាមសាលាខណ្ឌទាំង៨ កាលពីថ្ងៃទី២៧ ខែកក្កដា ដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ១.១៤០នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាសង្កាត់ ចំនួន៧៥ នាក់ និងសមាជិក សមាជិកាភូមិចូលរួមចំនួន ៩៦៨នាក់ ។

-ស្តីពី "ការលើកកម្ពស់សមត្ថភាពសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកសាងផែនការ និងការការពារ សុខភាពមាតា និងកុមារ" នៅភូមិភាគទី៧ ប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តព្រះសីហនុ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ១២៤នាក់ ក្នុងនោះមានតំណាងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមចំនួន ៥៦នាក់ ។

-ស្តីពី "សភា និងការជំរុញស្ត្រីក្នុងឆាកនយោបាយ" នៅភូមិភាគទី១ ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងត្បូងព្រឹទ្ធសភា (វិមានរដ្ឋចំការមន) កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១១ ដែលមានសមាសភាពចូលរួមសរុបចំនួន ១៧៤នាក់ ។

-ស្តីពី "ការបង្កើនសមាមាត្រស្ត្រីជាអ្នកដឹកនាំនៅថ្នាក់ក្រោមជាតិ" នៅភូមិភាគទី៨ ប្រព្រឹត្តទៅនៅសាលាខេត្តស្ទឹងត្រែង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ ដែលមានសមាសភាពចូលរួមចំនួន ១៨៤នាក់ ក្នុងនោះមានសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន ១៣៥នាក់ ។

-ស្តីពី "ភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងត្បូងព្រឹទ្ធសភា (វិមានរដ្ឋចំការមន) កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន ៩៩នាក់ ។

-ស្តីពី "ការដកបទពិសោធន៍អំពីលទ្ធផលនៃការរៀបចំវេទិកា និងការចុះបេសកកម្មរបស់ព្រឹទ្ធសភានៅតាមភូមិភាគ" ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងជើងព្រឹទ្ធសភា (វិមានរដ្ឋចំការមន) កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ៩៥នាក់ ។

-ស្តីពី "ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍" ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងជើងព្រឹទ្ធសភា (វិមានរដ្ឋចំការមន) កាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០ ដែលមានសមាសភាពចូលរួមសរុបចំនួន ១០១នាក់ ។

-ស្តីពី "ការរៀបចំរចនាសម្ព័ន្ធស្ថាប័នថ្នាក់ក្រោមជាតិ" ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងត្បូងព្រឹទ្ធសភា (វិមានរដ្ឋចំការមន) កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១ ដែលមានសមាសភាពចូលរួមសរុបចំនួន ១៦៥នាក់ ។

ក្នុងនីតិកាលទី២នេះ ថ្នាក់ដឹកនាំ គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការជំនាញ ក្រុមសមាជិកា និងសមាជិកព្រឹទ្ធសភា បានចុះទៅមណ្ឌលដើម្បីជួបប្រាស្រ័យសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ក្តាប់សំណូមពរ បញ្ហាកង្វល់នៅតាមភូមិភាគ ចុះសួរសុខទុក្ខ នាំយកថវិកា និងសម្ភារផ្សេងៗទៅជូនដល់កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិដែលឈរជើងនៅតាមតំបន់ព្រំដែន **សរុបចំនួន ៣១៦ លើក** ។

ជាមួយគ្នានេះដែរក្រុមសមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់សហការយ៉ាងល្អជាមួយនឹងក្រុមគ្រូពេទ្យស្ម័គ្រចិត្តវៀតណាម និងសប្បុរសជនវៀតណាម ក្រុមគ្រូពេទ្យចិន កូរ៉េ ជួយពិនិត្យ ព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ឧត្តរមានជ័យ កណ្តាល កំពង់ស្ពឺ កំពង់ចាម ក្រចេះ កំពង់ធំ ព្រៃវែង ស្វាយរៀង តាកែវ កំពត កែប ព្រះសីហនុ កោះកុង កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង សរុបចំនួន២៤លើក ដែលមានប្រជាពលរដ្ឋចំនួន ២១.៧៩២នាក់ ។

២-មុខងារនីតិកម្ម


ក្នុងមុខងារនីតិកម្ម ព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់លើអត្ថបទច្បាប់ ឬបញ្ហានានា ដែលរដ្ឋសភាបានបញ្ជូនមក ។ ជាក់ស្តែងក្នុងនីតិកាលទី២ ព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់លើអត្ថបទច្បាប់បានចំនួន

១៣៨ ក្នុងចំណោមអត្ថបទច្បាប់ចំនួន ១៥៦ ដែលរដ្ឋសភាបានបញ្ជូនមក ។

២-១ សម័យប្រជុំព្រឹទ្ធសភា

ក្នុងនីតិកាលទី២នេះ (២០០៦-២០១២) ព្រឹទ្ធសភា បានដំណើរការសម័យប្រជុំចំនួន ១០ លើក ប្រជុំចំនួន ៥០ លើក និងប្រជុំវិសាមញ្ញចំនួន ១១ លើក ។

សម័យប្រជុំ	ចំនួនប្រជុំ	ចំនួនច្បាប់
លើកទី១	០៥ លើក	០៥
វិសាមញ្ញ	០១ លើក	០៣
លើកទី២	០៦ លើក	២២
លើកទី៣	០៦ លើក	១៤
វិសាមញ្ញ	០២ លើក	០៥
លើកទី៤	០៨ លើក	២៣
វិសាមញ្ញ	០១ លើក	០១
លើកទី៥	០៣ លើក	០៧
វិសាមញ្ញ	០៥ លើក	១១
លើកទី៦	០៤ លើក	០៨
វិសាមញ្ញ	០១ លើក	០១
លើកទី៧	០៦ លើក	១១
វិសាមញ្ញ	០១ លើក	០១
លើកទី៨	០២ លើក	០៦
លើកទី៩	០៥ លើក	១២
លើកទី១០	០៥ លើក	០៨




២-២ សកម្មភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍

ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍បានប្រជុំ ចំនួន៦៧លើក ដើម្បីរៀបចំរបៀបវារៈ កំណត់កាលបរិច្ឆេទនៃការប្រជុំព្រឹទ្ធសភា និងជ្រើសរើសលេខាធិការសម្រាប់សម័យប្រជុំនីមួយៗ ព្រមទាំងពិនិត្យ និងសម្រេចអំពីការងារផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។

២-៣ តារាងសង្ខេបស្តីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំ	ដឹកនាំប្រជុំព្រឹទ្ធសភា	ដឹកនាំប្រជុំគ.ក.អចិន្ត្រៃយ៍	ប្រមុខរដ្ឋស្តីទី
សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធាន	៣២ លើក	៤៤ លើក	២០ លើក
សម្តេច **ស៊ីសុវត្ថិ ជីវនមុនីរ័ក្ស** អនុប្រធានទី ១	២១ លើក	២០ លើក	០១ លើក
ឯកឧត្តម **ទេព ងន** អនុប្រធានទី ២	០៤ លើក	០៣ លើក	០



២-៤ សកម្មភាពរបស់គណៈកម្មការជំនាញទាំង ៩

គណៈកម្មការជំនាញទាំង៩របស់ព្រឹទ្ធសភាបានបំពេញការងារយ៉ាងសកម្មស្របតាមតួនាទី ភារកិច្ច និង សមត្ថកិច្ចរបស់គណៈកម្មការនីមួយៗ ដោយបានដើរតួនាទីជាកូនព្រឹទ្ធសភាមួយ ដើម្បីសម្រេចឲ្យបាននូវមុខងារទាំង៣ ។ គណៈកម្មការជំនាញទាំង៩ បានពិនិត្យ ពិភាក្សាលើសេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ និងអត្ថបទច្បាប់ ព្រមទាំងបណ្តឹងតវ៉ាដូចខាងក្រោម ៖

-គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ច ចំនួន ៣៦៦ករណី និងបានធ្វើរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ០១ ។

-គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម បានប្រជុំផ្ទៃក្នុង និងអន្តរគណៈកម្មការ ដើម្បីរៀបចំរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ៣៤ ។

-គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន បានប្រជុំផ្ទៃក្នុង និងអន្តរគណៈកម្មការ ដើម្បីរៀបចំរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ២៧ ។

-គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ

បានប្រជុំផ្ទៃក្នុង និងអន្តរគណៈកម្មការ ដើម្បីរៀបចំរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ២៥។

-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន បានប្រជុំផ្ទៃក្នុង និងអន្តរគណៈកម្មការ ដើម្បីរៀបចំរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ០៨ ។

-គណៈកម្មការនីតិកម្ម និងយុត្តិធម៌ បានប្រជុំផ្ទៃក្នុង និងអន្តរគណៈកម្មការ ដើម្បីរៀបចំរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ២៣ ។

-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍ បានប្រជុំផ្ទៃក្នុង និងអន្តរគណៈកម្មការ ដើម្បីរៀបចំរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ០៥ ។

-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី បានប្រជុំផ្ទៃក្នុង និងអន្តរគណៈកម្មការ ដើម្បីរៀបចំរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ០៨ ។

-គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ជាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានប្រជុំផ្ទៃក្នុង និងអន្តរគណៈ កម្មការ ដើម្បីរៀបចំរបាយការណ៍ពិនិត្យឆ្លងយោបល់លើអត្ថបទច្បាប់ចំនួន ២៥ ។

២-៥ គណៈកម្មការពិសេសរបស់ព្រឹទ្ធសភា

ក្រៅពីគណៈកម្មការជំនាញទាំង៩ខាងលើ ព្រឹទ្ធសភាបានបង្កើតគណៈកម្មការ ពិសេសចំនួន០៣ ដូចខាងក្រោម ៖

-គណៈកម្មការទទួលបន្ទុករៀបចំសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ឆ្នាំ១៩៩៩

-គណៈកម្មការពិសេស ទទួលបន្ទុករៀបចំសេចក្តីស្នើច្បាប់ស្តីពីលក្ខន្តិកៈសមាជិក ព្រឹទ្ធសភា

-គណៈកម្មការពិសេស វាយតម្លៃស្ថាប័នបន្ទាប់ពីរយៈពេល១០ឆ្នាំ នៃកិច្ចដំណើរការ និងការអភិវឌ្ឍ ។

ទន្ទឹមនឹងនេះ ព្រឹទ្ធសភាបានបង្កើតអនុគណៈកម្មការអមគណៈកម្មការពិសេស វាយតម្លៃស្ថាប័នចំនួន៤ គឺ ៖

១.អនុគណៈកម្មការសិក្សាស្រាវជ្រាវច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

២.អនុគណៈកម្មការសិក្សាស្រាវជ្រាវបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិវិធី និងក្រមសីលធម៌

៣.អនុគណៈកម្មការសិក្សាស្រាវជ្រាវរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីសមាជរដ្ឋសភា និងព្រឹទ្ធសភា

៤.អនុគណៈកម្មការទទួលបន្ទុករៀបចំសំណុំឯកសារបន្ថែមពាក់ព័ន្ធនឹងសេចក្តីស្នើច្បាប់ ស្តីពីសមាជរដ្ឋសភា និងព្រឹទ្ធសភា ។

ជាពិសេសក្រោយការចូលជាធរមាននៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ព្រឹទ្ធសភាបានបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយសម្រាប់ព្រឹទ្ធសភា នីតិកាលទី២ និងគណៈកម្មការចំពោះកិច្ចរួមជាមួយនឹងរដ្ឋសភា ដើម្បីរៀបចំព្រាងបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា និងរៀបចំដំណើរការកិច្ចប្រជុំសមាជលើកដំបូង។

៣-មុខងារត្រួតពិនិត្យ

គណៈកម្មការជំនាញទាំង៩ បានចុះទៅតាមខេត្ត រាជធានី ទូទាំងប្រទេស ចំនួន ៧៧ លើក ដើម្បីពិនិត្យតាមដានការអនុវត្តច្បាប់ និងគោលនយោបាយផ្សេងៗ លើគ្រប់វិស័យនៅមូលដ្ឋាន ដែលក្នុងនោះមាន៖

-គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតបាន ១០ លើក

-គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្មបាន ១០ លើក

-គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និង

បរិស្ថានបាន ០៥ លើក

-គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈបាន ០៩ លើក


-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មានបាន ១៥ លើក

-គណៈកម្មការនីតិកម្ម និងយុត្តិធម៌បាន ០៥ លើក

-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍បាន ០៤ លើក

-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីបាន ១២ លើក

-គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់បាន ០៧ លើក។



៤-មុខងារព័ត៌មាន

ព្រឹទ្ធសភាបានចាត់បញ្ជូនគណៈប្រតិភូរបស់គណៈកម្មការ និងសមាជិក សមាជិកា ទៅបំពេញបេសកកម្មស្រាវជ្រាវស្វែងរកព័ត៌មាន នៅតាមស្ថាប័ន ក្រសួង មន្ទីរ សហគ្រាសសាធារណៈ តំបន់អភិវឌ្ឍន៍ ខេត្ត រាជធានី ក្រុង ហើយបានផ្តល់ព័ត៌មានទាំងនោះដល់ព្រឹទ្ធសភា អំពីសភាពការណ៍សិទ្ធិមនុស្ស សេដ្ឋកិច្ច សង្គម វប្បធម៌ សាសនា បរិស្ថាន និងតម្រូវការរបស់មូលដ្ឋាន ។

៥-ការងារទំនាក់ទំនងសាធារណៈ និងទំនាក់ទំនងអន្តរជាតិ

នៅក្នុងកិច្ចការសហប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិ ព្រឹទ្ធសភាបានបំពេញការងារយ៉ាងសកម្មក្នុងការចូលរួមអនុវត្តកាតព្វកិច្ចអន្តរជាតិ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងបណ្តាសភានៃប្រទេសក្នុងតំបន់ ក្រៅតំបន់ ក៏ដូចជាជាមួយនឹងអង្គការសភា និងអង្គការអភិវឌ្ឍន៍នានា សំដៅអភិវឌ្ឍស្ថាប័នព្រឹទ្ធសភាឱ្យក្លាយជាសភាប្រជាធិបតេយ្យ និងទំនើប ដើម្បីអាចធ្វើសមាហរណកម្មខ្លួនឯងទៅក្នុងសភាតំបន់ និងពិភពលោក។ ព្រឹទ្ធសភាបានចូលរួមជាប្រចាំក្នុងមហាសន្និបាតប្រចាំឆ្នាំ សិក្ខាសាលាតំបន់ កិច្ចប្រជុំនានាក្នុងក្របខ័ណ្ឌដូចជា IPU, AIPA, APF, APPF, ICT Global Parliament, AFPPD ក៏ដូចជារបស់សមាគមអគ្គលេខាធិការសភាពិភពលោក។ មិនតែប៉ុណ្ណោះនៅក្នុងនីតិកាលទី២ ព្រឹទ្ធសភាបានដើរតួនាទីជាសភាគំរូ ដោយហ៊ានធ្វើស្វ័យវាយតម្លៃទៅលើដំណើរការអនុវត្តការងាររបស់ខ្លួនរយៈពេល១០ឆ្នាំ ដោយផ្អែកទៅតាមស្តង់ដាររបស់សហភាពអន្តរសភា (IPU) និងបានលើកយកបទពិសោធន៍ និងលទ្ធផលនៃស្វ័យវាយតម្លៃនេះបង្ហាញនៅលើឆាក

អន្តរជាតិ តាមរយៈការធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក និង IPU។ ក្នុងការបំពេញកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ព្រឹទ្ធសភាក៏បានចូលរួមផ្តល់សច្ចាប័នទៅលើការអនុញ្ញាតឱ្យកម្ពុជាចូលជាភាគីនៃសន្ធិសញ្ញា អនុសញ្ញា និងពិធីសារនានា និងកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី។ ព្រឹទ្ធសភាបានចូលរួមតាមដាន និងជំរុញការអនុវត្តផែនការសកម្មភាពទីក្រុងប្រ៊ុសសែល (BPOA) ដែលធ្វើឡើងដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួច តាមរយៈការរៀបចំសិក្ខាសាលា និងតាមដានការអនុវត្តរបស់រដ្ឋាភិបាល ។

ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងសភា និងសភា ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានបានដឹកនាំគណៈប្រតិភូទៅបំពេញទស្សនកិច្ចផ្លូវការ និងដឹកស្រង់បទពិសោធន៍នៅសភាប្រទេសជាមិត្ត សំដៅពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ពង្រឹងសមត្ថភាពសភា និងទាក់ទាញកេជំនួយដើម្បីអភិវឌ្ឍស្ថាប័ន ។ ក្នុងនីតិកាលទី២នេះ ថ្នាក់ដឹកនាំព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាន បានដឹកនាំគណៈប្រតិភូកម្ពុជា ទៅបំពេញទស្សនកិច្ចនៅប្រទេសជាច្រើនដូចជា នៅសាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសបារាំង អូស្ត្រាលី ជប៉ុន កាណាដា សាធារណរដ្ឋកូរ៉េ រុស្ស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ប៉ាណាម៉ា ជាដើម ។ ឯព្រឹទ្ធសភាក៏បានរៀបចំទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ សមាជិក សមាជិកាសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៃសភាប្រទេសជាមិត្តផងដែរ ដូចជាប្រធាន និងអនុប្រធានសភាពិគ្រោះយោបល់នយោបាយប្រជាជនចិន ប្រធានព្រឹទ្ធសភា អូស្ត្រាលី អនុប្រធានព្រឹទ្ធសភាបារាំង អនុប្រធានសភាក្រុមប្រឹក្សាតំបន់ឥណ្ឌូនេស៊ី អគ្គលេខាធិការសភាស៊ុយអែត ប្រធានគណៈកម្មការកិច្ចការបរទេសព្រឹទ្ធសភាថៃ សមាជិកព្រឹទ្ធសភាអូស្ត្រាលី ។ល។ ផ្តើមចេញពីដំណើរទស្សនកិច្ច និងកិច្ចសហប្រតិបត្តិការខាងលើ ព្រឹទ្ធសភាបានទទួលជំនួយឧបត្ថម្ភជាបន្តបន្ទាប់ពីបណ្តារដ្ឋាភិបាល និងសភានៃបណ្តាប្រទេសជាមិត្តក្នុងការជួយអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា ទាំងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ សម្ភារបរិក្ខារនានា និងធនធានមនុស្ស ដែលមានទឹកប្រាក់សរុបចំនួន **១០.២០៥.៨៤៣** ដុល្លារអាមេរិក ដែលក្នុងនោះមាន ៖

-រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានជួយជួសជុលឡើងវិញអគារការិយាល័យរបស់សមាជិកព្រឹទ្ធសភា ០៣ខ្នង មាន៧២បន្ទប់ ជួសជុលសាលប្រជុំពេញអង្គព្រឹទ្ធសភាបច្ចុប្បន្ន អគារខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា និងសាងសង់អគារ០៣ខ្នង កម្ពស់០៣ជាន់ ព្រមទាំងផ្តល់ជំនួយជាកុំព្យូទ័រចំនួន៩៧គ្រឿង ម៉ាស៊ីនត្រជាក់ចំនួន៩៧គ្រឿង និងសម្ភារបរិក្ខារការិយាល័យជាច្រើន ដែលមានទឹកប្រាក់ចំនួន **៩.២៩០.000** ដុល្លារអាមេរិក។

-រដ្ឋាភិបាលជប៉ុន បានផ្តល់ជំនួយសម្រាប់សាងសង់អគារការិយាល័យថ្មីចំនួន០២ខ្នង កម្ពស់០៣ជាន់ និងបំពាក់សម្ភារការិយាល័យ និង Studio ដែលមានទឹកប្រាក់សរុបចំនួន **៣00.៣៤៣**ដុល្លារអាមេរិក។

-ព្រឹទ្ធសភា និងរដ្ឋាភិបាលសាធារណរដ្ឋបារាំង និងសមាគមសភានៃប្រទេសប្រើប្រាស់ភាសាបារាំង ផ្តល់សម្ភារការិយាល័យ ដែលមានទឹកប្រាក់សរុបចំនួន **៣១.៩00**ដុល្លារអាមេរិក។

-រដ្ឋាភិបាល និងរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ផ្តល់ជំនួយជាសម្ភារការិយាល័យ និងកម្រាលព្រំមានទឹកប្រាក់សរុបចំនួន **១៥៥.000**ដុល្លារអាមេរិក។

-សាធារណរដ្ឋកូរ៉េ ផ្តល់ជំនួយជាកុំព្យូទ័រចំនួន១៨0គ្រឿង ដែលមានទឹកប្រាក់ចំនួន **២៨.៦00**ដុល្លារអាមេរិក។

ចំពោះការជួយអភិវឌ្ឍធនធានមនុស្ស មន្ត្រីព្រឹទ្ធសភាត្រូវបានទទួលឱ្យទៅបំពេញទស្សនកិច្ចសិក្សា និងធ្វើកម្មសិក្សានៅសភាបរទេសដូចជា នៅព្រឹទ្ធសភាបារាំង សភាកាណាដា សភាអូស្ត្រាលី រុស្ស៊ី និងបាន

ទទួលអាហារូបករណ៍ និងទស្សនកិច្ចសិក្សានៅប្រទេសជាច្រើនដូចជា ប្រទេសអូស្ត្រាលី បារាំង កាណាដា អ៊ីតាលី នូវែលហ្សេឡង់ ជប៉ុន ស៊ុយអែត ហ្វីលីពីន ឥណ្ឌា ចិន ថៃ សិង្ហបុរី តួកា ឡាវ ឥណ្ឌូនេស៊ី និងវៀតណាម ជាដើម ។ ក្រៅពីនេះព្រឹទ្ធសភា ក៏បានទទួលអ្នកឯកទេសនៃសភាប្រទេសជាមិត្ត (ស៊ុយអែត, រុស្ស៊ី) មកបណ្តុះបណ្តាល មន្ត្រីព្រឹទ្ធសភាលើជំនាញសំខាន់ៗដូចជា ការងាររបស់លេខាធិការដ្ឋានគណៈកម្មការ ជំនាញស្រាវជ្រាវ និងវិភាគច្បាប់ សេដ្ឋកិច្ច ព័ត៌មានវិទ្យា ការធ្វើផែនការ និងកសាងគម្រោង ការងារទំនាក់ទំនងសាធារណៈ និងប្រាស្រ័យទាក់ទង ការគ្រប់គ្រងធនធានមនុស្ស ។ល។

ក្រៅពីការពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌសភា និងអង្គការសភា ព្រឹទ្ធសភាក៏បានពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយនឹងដៃគូអភិវឌ្ឍន៍នានា ដូចជាកម្មវិធីអភិវឌ្ឍន៍សហប្រជាតិ (UNDP) គម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា (CCLSP) របស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា មូលនិធិខុនរ៉ាដ អាឌិនណៅអ៊ែរ (KAS) សភាប្រឹក្សាបារាំង (APF) មូលនិធិអាស៊ី (Asia Foundation) អង្គការសេវាអ្នកឯកទេសជាន់ខ្ពស់អាល្លឺម៉ង់ (SES) និង CIM ។ល។ តាមរយៈដៃគូអភិវឌ្ឍន៍ខាងលើ ព្រឹទ្ធសភាបានទទួលការជួយជ្រោមជ្រែង ជាពិសេសលើការពង្រឹងសមត្ថភាពសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីអគ្គលេខាធិការដ្ឋាន ដើម្បីជួយលើកកម្ពស់ប្រសិទ្ធភាពការងាររបស់មន្ត្រីក្នុងការផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារទាំងបីរបស់ព្រឹទ្ធសភា រួមមានមុខងារនីតិកម្ម មុខងារត្រួតពិនិត្យ និងមុខងារតំណាងឱ្យកាន់តែប្រសើរ ។ ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងការពង្រឹងសមត្ថភាព និងលើកកម្ពស់សមត្ថភាពព្រឹទ្ធសភាកម្ពុជា ធ្វើឡើងតាមរយៈការរៀបចំសិក្ខាសាលា វេទិកា កិច្ចប្រជុំពិភាក្សាតុមូល វគ្គបណ្តុះបណ្តាល ដែលសរុបក្នុងមួយនីតិកាលនេះមានចំនួន **៦៨** លើក ។ ក្រៅពីនេះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិតាមរយៈកម្មវិធីគាំទ្រនីតិប្បញ្ញត្តិកម្ពុជាបានរៀបចំកម្មវិធីទស្សនកិច្ចសិក្សារបស់សិស្សមកកាន់ព្រឹទ្ធសភាជាច្រើនលើក ដើម្បីឱ្យសាធារណជនបានដឹងពីការងាររបស់អង្គនីតិប្បញ្ញត្តិ និងផ្សារភ្ជាប់អង្គនីតិប្បញ្ញត្តិឱ្យកាន់តែជិតស្និទ្ធជាមួយនឹងសាធារណជន ។

នាបុងនីតិកាលទី២នេះ ដៃគូអភិវឌ្ឍន៍របស់ព្រឹទ្ធសភាកម្ពុជាមួយចំនួនបានបញ្ចប់គម្រោងរបស់ខ្លួនជាមួយនឹងស្ថាប័ននីតិប្បញ្ញត្តិ ក្នុងនោះមានគម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា (CCLSP) និងគម្រោង LEAP របស់ UNDP ។ ការដកថយរបស់ដៃគូអភិវឌ្ឍន៍គឺជាការគម្រាមកំហែងមួយចំពោះដំណើរការអភិវឌ្ឍរបស់ព្រឹទ្ធសភា ។ ដើម្បីឆ្លើយតបទៅនឹងនិន្នាការនេះ ព្រឹទ្ធសភាបានផ្តួចផ្តើមបង្កើតវិទ្យាស្ថានសភាកម្ពុជា ដើម្បីធ្វើជាយន្តការបន្តពង្រឹងពង្រីកសមត្ថភាពសភាកម្ពុជា ។ មិនត្រឹមតែប៉ុណ្ណោះនាពេលអនាគតតាមរយៈវិទ្យាស្ថាននេះ សភាកម្ពុជាសង្ឃឹមនឹងអាចចែករំលែកនូវបទពិសោធន៍របស់ខ្លួនជាមួយនឹងស្ថាប័នសភានៃប្រទេសនានានៅក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ។

វិសាលភាពនៃការងារសហប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិរបស់ព្រឹទ្ធសភាពីមួយនីតិកាលទៅមួយនីតិកាលកាន់តែត្រូវបានពង្រឹង និងពង្រីក ហើយកិត្យានុភាពរបស់ព្រឹទ្ធសភាកម្ពុជាកាន់តែត្រូវបានទទួលការគាំទ្រ និងទទួលស្គាល់នៅលើឆាកអន្តរជាតិ។ ជាងនេះទៅទៀតសមិទ្ធផលខាងលើ ក៏បានឆ្លុះបញ្ចាំងកាន់តែច្បាស់ដែរថា ក្នុងដំណើរការអភិវឌ្ឍរបស់ព្រឹទ្ធសភា ទាំងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍធនធានមនុស្ស ព្រឹទ្ធសភាពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើជំនួយអន្តរជាតិ និងរបស់ដៃគូអភិវឌ្ឍន៍។ មិនតែប៉ុណ្ណោះព្រឹទ្ធសភាកម្ពុជា បានត្រៀមឱ្យមានយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការឆ្លើយតបទៅនឹងការដកថយរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីធានានូវដំណើរការអភិវឌ្ឍរបស់ខ្លួនឱ្យឈានទៅដល់គោលដៅជាសភាប្រជាធិបតេយ្យទំនើបនិងអាចធ្វើសមាហរណកម្មខ្លួនទៅក្នុងសភាតំបន់ និងពិភពលោក ។

(សូមមើលតារាងឧបសម្ព័ន្ធ ស្តីពីតួលេខនៃលទ្ធផលកិច្ចសហប្រតិបត្តិការអន្តរជាតិព្រឹទ្ធសភា នីតិកាលទី២)



រូបភាពស្តីពី
សកម្មភាពរបស់ថ្នាក់ដឹកនាំ
និងសមាជិក សមាជិការព្រឹទ្ធសភា
ឆ្នាំ ២០០៦-២០១២

សកម្មភាពពិនិត្យច្បាប់ (សម័យប្រជុំពេញអង្គ)













សកម្មភាពពិនិត្យច្បាប់ (កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍)









សកម្មភាពរបស់គណៈកម្មការជំនាញក្នុងការពិភាក្សាច្បាប់







សកម្មភាពរបស់គណៈកម្មការជំនាញក្នុងការពិភាក្សាច្បាប់







សកម្មភាពរបស់គណៈកម្មការជំនាញក្នុងការពិភាក្សាច្បាប់







វេទិកាស្តីពី "សិទ្ធិមនុស្ស និងការគោរពច្បាប់នៅមូលដ្ឋាន វិមជ្ឈការ វិសហមជ្ឈការ និង តាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅវិមានព្រឹទ្ធសភា (ថ្ងៃទី០៧ ខែឆ្នូ ឆ្នាំ២០០៧)





វេទិកាស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងតាពជាតំណាងផលប្រយោជន៍ ឃុំ-សង្កាត់" នៅភូមិភាគទី៨ ខេត្តក្រចេះ (ថ្ងៃទី១៧-១៨ ខែមីនា ឆ្នាំ២០០៩)









សេចក្តីប្រកាសព័ត៌មានស្តីពី "ព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយពាណិជ្ជកម្ម វិនិយោគ និងឧស្សាហកម្ម" នៅវិមានព្រឹទ្ធសភា (ថ្ងៃទី០៥-០៦ ខែឧសភា ឆ្នាំ២០១១)



សេចក្តីប្រកាសព័ត៌មានស្តីពី "ការលើកកម្ពស់ផលប្រយោជន៍ឃុំ សង្កាត់ លើការអនុវត្តគោលនយោបាយ ពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា" នៅវិមានព្រឹទ្ធសភា (ថ្ងៃទី០៣-០៤ ខែវិច្ឆិកា ឆ្នាំ២០០៨)





វេទិកាស្តីពី "ព្រឹទ្ធសភា និងផលប្រយោជន៍ក្រុមប្រឹក្សាឃុំ សង្កាត់" នៅភូមិភាគទី៥ ខេត្តតាកែវ (ថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០)







វេទិកាស្តីពី "ព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហ-មជ្ឈការ និងយេនឌ័រ" នៅភូមិភាគទី៨ ខេត្តកំពង់ធំ (ថ្ងៃទី២២-២៣ ខែមិថុនា ឆ្នាំ២០១១)







វេទិកាសមាជិកាស្តីពី "ការលើកកម្ពស់យេនឌ័រ និងការបង្កើនភាពអង់អាចដល់សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់" នៅតំបន់ភាគទី៤ ខេត្តប៉ៃលិន (ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០០៩)





វេទិកាសមាជិកាស្តីពី "ការលើកកម្ពស់សមត្ថភាពសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការចូលរួមធ្វើសេចក្តីសម្រេចនៅថ្នាក់ក្រោមជាតិ" នៅតំបន់ភាគទី៣ ខេត្តកណ្តាល (ថ្ងៃទី១៥-១៦ ខែកក្កដា ឆ្នាំ២០១០)





វេទិកាសមាជិកាស្តីពី "ការលើកកម្ពស់សមត្ថភាពសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីស្វែងយល់ និងអភិវឌ្ឍតាមតំបន់ទំនាបទន្លេមេគង្គ" នៅភូមិភាគទី២ ខេត្តកំពង់ចាម (ថ្ងៃទី០១-០២ ខែមិថុនា ឆ្នាំ២០១០)







សិក្ខាសាលាស្តីពី "សតា និងការជំរុញស្ត្រីក្នុងឆាកនយោបាយ" នៅវិមានព្រឹទ្ធសភា (ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១១)





កិច្ចពិភាក្សាស្តីពី "ការលើកកម្ពស់សមត្ថភាពរបស់សមាជិកាសង្កាត់ ក្នុងការចូលរួមចំណែកអភិវឌ្ឍមូលដ្ឋាន" នៅទីអាន់ព្រឹទ្ធសភា (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩)





ពិធីសំណេះសំណាលរវាងសមាជិកាព្រឹទ្ធសភា ជាមួយនឹងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ នៅភូមិភាគទី៨ ខេត្តព្រះវិហារ (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩)







លោកជំទាវ ធី ម៉ូស៊ី ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងលោកជំទាវ
ម៉ាន សំអាន លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តកូរ៉េ និងភៀតណាម
ចុះពិនិត្យព្យាបាលជំងឺ និងចែកអំណោយជូនដល់ប្រជាពលរដ្ឋ នៅតាមបណ្តាខេត្តនានា







សកម្មភាពចុះមូលដ្ឋានរបស់គណៈកម្មការជំនាញ

គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មដើម្បីសិក្សាស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស និងការអនុវត្តច្បាប់ ព្រមទាំងពិនិត្យ និងប្រមូលព័ត៌មានដែលទាក់ទងនឹងពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ នៅខេត្តកណ្តាល និងខេត្តតាកែវ កាលពីថ្ងៃទី២៩-៣០ ខែមីនា ឆ្នាំ២០១១



គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅខេត្តស្វាយរៀង ដើម្បីស្វែងយល់អំពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៩ ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងតំបន់សេដ្ឋកិច្ចពិសេស កាលពីថ្ងៃទី០១-០៣ ខែកញ្ញា ឆ្នាំ២០១០



គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មដើម្បីសិក្សាស្វែងយល់ និងប្រមូលព័ត៌មានអំពីប្រព័ន្ធធារាសាស្ត្រ កសិកម្ម វិនិយោគ និងតំបន់អភិវឌ្ឍន៍ នៅខេត្តបាត់ដំបង កាលពីថ្ងៃទី២៤-២៦ ខែឧសភា ឆ្នាំ២០១០





សកម្មភាពចុះមូលដ្ឋានរបស់គណៈកម្មការជំនាញ

គណៈប្រតិភូព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា
អញ្ជើញចូលរួមក្នុងដំណើរបេសកកម្មស្តីពី "ការបញ្ជ្រាបយេនឌ័រ និងបញ្ហាគណនេយ្យភាព នៅឃុំ សង្កាត់"
នៅខេត្តកោះកុង កាលពីថ្ងៃទី០៨-១១ ខែកុម្ភៈ ឆ្នាំ២០១០



គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មសិក្សាស្វែងយល់
អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន
នៅច្រកទ្វារព្រំដែនជ្រៃធំ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១០



គណៈប្រតិភូគណៈកម្មការទី៦ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មដើម្បីសិក្សាស្វែងយល់
ពីវិធានទាំងឡាយនៃការដោះស្រាយវិវាទក្នុង និងក្រៅប្រព័ន្ធតុលាការ និងការអនុវត្តច្បាប់ នៅខេត្តកោះកុង
កាលពីថ្ងៃទី០៩-១១ ខែមិថុនា ឆ្នាំ២០១០



សកម្មភាពចុះមូលដ្ឋានរបស់គណៈកម្មការជំនាញ

គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មក្នុងការប្រមូលព័ត៌មានអំពីវិស័យទទួលបន្ទុកជាពិសេសវិស័យទេសចរណ៍ និងជួបប្រាស្រ័យជាមួយនឹងម្ចាស់ឡោត នៅខេត្តកែប កំពត និងព្រះសីហនុ កាលពីថ្ងៃទី១៤-១៧ ខែធ្នូ ឆ្នាំ២០០៩



គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មដើម្បីជំរុញការអនុវត្ត និងផ្សព្វផ្សាយច្បាប់ស្តីពី "ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍-ជំងឺអេដស៍" នៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៥-១៧ ខែកញ្ញា ឆ្នាំ២០១០



គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មរ៉ែ រោងចក្រ សហគ្រាស និងសិប្បកម្មខ្នាតមធ្យម ខ្នាតតូច និងការអនុវត្តគោលនយោបាយចុះបញ្ជីដី និងប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិច នៅខេត្តស្ទឹងត្រែង និងរតនគិរី កាលពីថ្ងៃទី២៤-២៨ ខែវិច្ឆិកា ឆ្នាំ២០០៩



សកម្មភាពសិក្ខាសាលា







ថ្នាក់ដឹកនាំព្រឹទ្ធសភា ធ្វើសវនាការជាមួយនឹងប្រមុខរដ្ឋ ថ្នាក់ដឹកនាំសភា នាយករដ្ឋមន្ត្រី ឥស្សរជនជាន់ខ្ពស់ និងអន្តទូតនៃបណ្តាប្រទេសនានា



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានាធិបតីនៃប្រទេសទីម័រខាងកើត



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងអគ្គលេខាធិការបក្សកុំមុយនីស្តវៀតណាម



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានាធិបតីនៃ
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានាធិបតីនៃ
សាធារណរដ្ឋឥណ្ឌា



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានាធិបតីនៃប្រទេសស្លូវ៉ាគី



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងអនុប្រធានាធិបតីចិន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មាធិការជាតិ
សភាប្រឹក្សានយោបាយប្រជាជនចិន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានព្រឹទ្ធសភាអូស្ត្រាលី



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាវៀតណាម



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មាធិការ
អចិន្ត្រៃយ៍សភាតំណាងប្រជាជនចិន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាឡាវ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាថៃ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងអតីតប្រធានាធិបតីវៀតណាម



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងអតីតអគ្គលេខាធិការ
មជ្ឈិមបក្សកុំមុយនីស្តវៀតណាម



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃ
សាធារណរដ្ឋសង្គមនិយមវៀតណាម



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃ
សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងនាយករដ្ឋមន្ត្រីនៃសហភាពមីយ៉ាន់ម៉ា



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីថៃ




សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងនាយករដ្ឋមន្ត្រីនៃប្រទេសគូវ៉ែត



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី




សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃ
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងអតីតនាយករដ្ឋមន្ត្រីនៃ
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងលេខាគណៈកម្មាធិការកិច្ចការនយោបាយ និងច្បាប់នៃគណៈកម្មាធិការមជ្ឈិមបក្សកុំមុយនីស្តចិន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងអនុប្រធានសភាក្រុមប្រឹក្សាតំបន់នៃ
សាធារណរដ្ឋឥណ្ឌូនេស៊ី



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងប្រធានគណៈកម្មការហិរញ្ញវត្ថុ
និងសេដ្ឋកិច្ចនៃសភាអ៊ឺរ៉ុប



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងប្រធានមូលនិធិ
ខុនរ៉ាដអាឌិនណៅអ៊ែរ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងគណៈប្រតិភូរដ្ឋសភាកូរ៉េ



សម្តេច **ស៊ីសុវត្ថិ ជីវ័ន្តមុនីវ័ង្ស** អនុប្រធានទី១ព្រឹទ្ធសភា
និងប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម




សម្តេច **ស៊ីសុវត្ថិ ជីវ័ន្តមុនីវ័ង្ស** អនុប្រធានទី១ព្រឹទ្ធសភា
និងគណៈប្រតិភូមិត្តភាពសភាកម្ពុជា-អ៊ីរ៉ង់



សម្តេច **ស៊ីសុវត្ថិ ជីវ័ន្តមុនីវ័ង្ស** អនុប្រធានទី១ព្រឹទ្ធសភា
និងគណៈប្រតិភូសាកលវិទ្យាល័យរូស៊ុក
នៃសាធារណរដ្ឋកូរ៉េ




ឯកឧត្តម **ងោ ចន** អនុប្រធានទី២ព្រឹទ្ធសភា
និងលោកជំទាវអនុប្រធានព្រឹទ្ធសភាបារាំង



ឯកឧត្តម **ងោ ចន** អនុប្រធានទី២ព្រឹទ្ធសភា
និងអនុប្រធានរដ្ឋសភាវៀតណាម



ឯកឧត្តម **ងោ ចន** អនុប្រធានទី២ព្រឹទ្ធសភា
និងគណៈប្រតិភូព្រឹទ្ធសភាថៃ



ឯកឧត្តម **ងោ ចន** អនុប្រធានទី២ព្រឹទ្ធសភា
និងគណៈប្រតិភូវិទ្យាស្ថានបច្ចេកវិទ្យាព័ត៌មានចិន



ឯកឧត្តម **ងោ ចន** ប្រធានព្រឹទ្ធសភាស្តីទី
និងតំណាងមូលនិធិឧនរ៉ាដអាឌិនណៅអែរ ប្រចាំកម្ពុជា



ឯកឧត្តម **ងោ ចន** អនុប្រធានទី២ព្រឹទ្ធសភា
និងអនុប្រធានសភាប្រឹក្សាពិគ្រោះនយោបាយប្រជាជនចិន




សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ




សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី ទទួលសារតាំងពីឯកអគ្គរដ្ឋទូត
នៃសាធារណរដ្ឋប្រជាមានិតចិន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងអតីតឯកអគ្គរដ្ឋទូត
នៃសាធារណរដ្ឋប្រជាមានិតចិន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរាជទូតជប៉ុន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតនៃ
សាធារណរដ្ឋសង្គមនិយមវៀតណាម




សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតនៃប្រទេសអ៊ីស្រាអែល



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសិង្ហបុរី



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប៉ូឡូញ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងឯកអគ្គរដ្ឋទូតនៃ
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរាជទូត
នៃព្រះរាជាណាចក្រថៃ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរាជទូតនៃប្រទេសប្រ៊ុយណេ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងឯកអគ្គរដ្ឋទូត
នៃសាធារណរដ្ឋឥណ្ឌូនេស៊ី



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី និងឯកអគ្គរដ្ឋទូត
នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា និងឯកអគ្គរដ្ឋទូតនៃសហភាពមីយ៉ាន់ម៉ា



សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស** អនុប្រធានទី១ព្រឹទ្ធសភា
និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគូបា



សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស** អនុប្រធានទី១ព្រឹទ្ធសភា
និងឯកអគ្គរដ្ឋទូតនៃប្រទេសអាល្លឺម៉ង់

ថ្នាក់ដឹកនាំព្រឹទ្ធសភា បំពេញទស្សនកិច្ចនៅបរទេស



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការជាមួយនឹងឯកឧត្តម Wu BANGGUA ប្រធានសភាប្រជាជនចិន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការជាមួយនឹងឯកឧត្តម Jia QINGLIN ប្រធានគណៈកម្មាធិការជាតិសភាប្រឹក្សានយោបាយប្រជាជនចិន



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការជាមួយនឹងឯកឧត្តម Nong DUC MANH អគ្គលេខាធិការបក្សកុំមុយនីស្តវៀតណាម



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការជាមួយនឹងឯកឧត្តម Nguyen PHU TRONG ប្រធានរដ្ឋសភាវៀតណាម



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលគ្រឿងឥស្សរិយយស "មាស" ខ្ពស់បំផុតពីឯកឧត្តម **ជុម ម៉ាលី សៃញ៉ាសន** ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការជាមួយនឹងឯកឧត្តម **ចន ស៊ីង ចាំម៉ាន់ឆេង** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ចុះមូលដ្ឋាន

សម្តេចអគ្គមហាធម្មពោធិសាលកិត្តិព្រឹទ្ធបណ្ឌិត **ជា ស៊ីម** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមក្នុងពិធីបុណ្យផ្សេងៗ នៅតាមខេត្ត ក្រុងនានា











សម្តេច **ស៊ីសុវត្ថិ ជីវ័ន្តមុនីរ័ក្ស** អនុប្រធានទី១ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានយាងជាព្រះអធិបតីក្នុងពិធីសម្ពោធផ្លូវក្រាលឥដ្ឋការ៉ូ ក្នុងបរិវេណវត្តជ្រោយពិសី ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល



ឯកឧត្តម **ឡេង ឆន** អនុប្រធានទី២ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមក្នុងពិធីបុណ្យផ្សេងៗ នៅតាមខេត្ត ក្រុងនានា ព្រមទាំងនាំយកអំណោយទៅចែកជូនដល់កងកម្លាំងប្រដាប់អាវុធ ដែលឈរជើងការពារនៅតាមតំបន់ព្រំដែន









ពិធីសម្ពោធអគារការិយាល័យពីរខ្នង កម្ពស់បីជាន់ និងពិធីប្រគល់-ទទួលសម្ភារការិយាល័យ ជាជំនួយរបស់រដ្ឋាភិបាលជប៉ុន ជូនដល់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា







ពិធីបញ្ចុះបឋមសិលាសាងសង់ និងដួសដុលអគារ ជាជំនួយរបស់រដ្ឋាភិបាលចិន ជូនដល់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា



៦-លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា


អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានតួនាទីជាសេនាធិការផ្តាល់ឲ្យព្រឹទ្ធសភា រ៉ាប់រងរាល់កិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗនៅក្នុង និងក្រៅស្ថាប័ន។

ក. គោលការណ៍គ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានយន្តការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ បើកចំហ និងមានតម្លាភាព ។ ជាទូទៅការរៀបចំលិខិតបទដ្ឋាន គោលនយោបាយផ្សេងៗ សម្រាប់ការដឹកនាំគ្រប់គ្រងត្រូវបានប្រគល់ជូនគណៈកម្មការ ដែលមានសមាសភាពចម្រុះមកពីគ្រប់អង្គភាពចំណុះ ហើយជាមន្ត្រីរាជការដែលមានបទពិសោធន៍ក្នុងការងារ ។

អនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រមនីតិប្បញ្ញត្តិ បទប្បញ្ញត្តិបន្ទាន់មួយចំនួនត្រូវបានរៀបចំឡើងដើម្បីបម្រើសេចក្តីត្រូវការចាំបាច់ក្នុងការដឹកនាំ និងគ្រប់គ្រងធនធានមនុស្ស និងការគិតគូរពីផលប្រយោជន៍មន្ត្រីរាជការ ដើម្បីជានាបានគូវការអភិវឌ្ឍស្ថាប័នបានជាប់លាប់យូរអង្វែង។


នៅក្នុងឆ្នាំ២០១០ អគ្គលេខាធិការដ្ឋាន បានកែសម្រួលរចនាសម្ព័ន្ធថ្មី មានដូចខាងក្រោម ៖



អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានមន្ត្រីបម្រើការងារទាំងអស់រួមមាន ៖ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងអ្នកហាត់ការ ។

-តារាងតួលេខមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងអ្នកហាត់ការ ៖

ឆ្នាំ	២០០៦	២០០៧	២០០៨	២០០៩	២០១០	២០១១
មន្ត្រីរាជការ	២៨៣	២៨៣	២៨៧	៤២០	៤១៥	៥៣៩
ប.ជាប់កិច្ចសន្យា	១៤០	១៤៨	១៨២	៩៣	៩៥	៩៣
អ្នកហាត់ការ	១៣៦	១៥២	១៣៩	១៤០	២២៤	២១១



ស្ថិតិមន្ត្រី បុគ្គលិកតាមសញ្ញាបត្រ ៖

-មន្ត្រីក្របខ័ណ្ឌ ៖

សញ្ញាបត្រ/ឆ្នាំ	២០០៦	២០០៧	២០០៨	២០០៩	២០១០	២០១១	ផ្សេងៗ
បណ្ឌិត					១	១	
អនុបណ្ឌិត	២៤	២៦	២៩	៧៤	៨៥	១១២	
បរិញ្ញាបត្រ	១១១	១២៣	១១៨	១៩២	២០២	២៦១	
បរិញ្ញាបត្រង	២៦	១២	១៨	៣២	២៦	៤១	
ទុតិយភូមិ	២៥	២៥	២៥	២៥	១៨	២៧	
ក្រោមទុតិយភូមិ	៩៧	៩៧	៩៧	៩៧	៨៣	៩៧	
សរុប	២៨៣	២៨៣	២៨៧	៤២០	៤១៥	៥៣៩	

-<u>បុគ្គលិកជាប់កិច្ចសន្យា</u> ៖

សញ្ញាបត្រ/ឆ្នាំ	២០០៦	២០០៧	២០០៨	២០០៩	២០១០	២០១១	ផ្សេងៗ
បណ្ឌិត						១	
អនុបណ្ឌិត	៥	៦	១២	១៨	១៨	១៧	
បរិញ្ញាបត្រ	៥០	៥៤	៧១	៤៣	៤៥	៥៣	
បរិញ្ញាបត្រវង	៥០	៥៣	៦៤	១៤	១៤	១០	
ទុតិយភូមិ	២៥	២៥	២៣	១២	១២	៧	
ក្រោមទុតិយភូមិ	១០	១០	១២	៦	៦	៥	
សរុប	១៤០	១៤៨	១៨២	៩៣	៩៥	៩៣	

-<u>អ្នកហាត់ការ</u> ៖

សញ្ញាបត្រ/ឆ្នាំ	២០០៦	២០០៧	២០០៨	២០០៩	២០១០	២០១១	ផ្សេងៗ
បណ្ឌិត							
អនុបណ្ឌិត	៣	៥	៨	១៤	៤២	៤៨	
បរិញ្ញាបត្រ	៥៨	៦៧	៦៤	៥៧	៨៩	១០១	
បរិញ្ញាបត្រវង	៣២	៣៦	៣០	២៨	៣៣	១៨	
ទុតិយភូមិ	២៥	៣២	២៣	២៦	៣៧	៣៥	
ក្រោមទុតិយភូមិ	១៨	១២	១៤	១៥	២៣	៩	
សរុប	១៣៦	១៥២	១៣៩	១៤០	២២៤	២១១	

ក្នុងការអភិវឌ្ឍស្ថាប័ន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានកសាងឯកសារជាមូលដ្ឋានដូចតទៅ ៖

- ផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៣-២០០៨ និងឆ្នាំ ២០០៩-២០១៣ ដែលមាន៥គោលដៅយុទ្ធសាស្ត្រ គឺ ៖
  - ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស
  - រចនាសម្ព័ន្ធ ប្រព័ន្ធគោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រង
  - ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
  - ការផ្សព្វផ្សាយព័ត៌មាន
  - ទំនាក់ទំនងជាមួយនឹងស្ថាប័នជាតិ និងអន្តរជាតិ ។
- ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា រយៈពេល ១០ឆ្នាំ(២០០៨-២០១៨) ដែលចែកចេញជា :

១. ផែនការសកម្មភាពរយៈពេលខ្លី (២០០៨-២០០៩) ដែលផ្តោតលើ ៖

- ការពង្រឹងតួនាទីរបស់ព្រឹទ្ធសភា
- ការពង្រឹងពង្រីកធនធានមនុស្ស និងការអភិវឌ្ឍស្ថាប័ន ។

២. ផែនការសកម្មភាពរយៈពេលមធ្យម (២០១០-២០១៣) ដែលផ្តោតលើ ៖

- ការបណ្តុះបណ្តាលសម្រាប់សមាជិកព្រឹទ្ធសភាថ្មី
- ការពិនិត្យមើលរបៀបរបបពិនិត្យអត្ថបទច្បាប់ ឬសេចក្តីស្នើច្បាប់
- ការចូលរួមរបស់សភានៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់តាំងពីដំណាក់កាលដំបូង
- ផែនការយុទ្ធសាស្ត្រថ្នាក់គណៈកម្មការជំនាញ
- ការពង្រឹងតួនាទីរៀបចំ និងតាមដានថវិកាព្រមទាំងការតាមដានការវិវឌ្ឍសេដ្ឋកិច្ច សង្គម និង វប្បធម៌
- ការពង្រីកទំនាក់ទំនងសាធារណៈ
- ភាពជាតំណាងរបស់ព្រឹទ្ធសភា
- កម្មវិធីបណ្តុះបណ្តាលទូទៅ ។

៣. ផែនការសកម្មភាពរយៈពេលវែង (២០១៤-២០១៨) ដែលផ្តោតលើ ៖

- ការបង្កើតមជ្ឈមណ្ឌលសភា
- ការបន្តពង្រឹងតួនាទីរៀបចំ និងតាមដានថវិកា និងការវិវឌ្ឍសេដ្ឋកិច្ច សង្គម និង វប្បធម៌
- ការអភិវឌ្ឍសមត្ថភាពសវនកម្មរបស់ព្រឹទ្ធសភា
- ការជានាសមត្ថភាពធ្វើជាតំណាងរបស់សមាជិកព្រឹទ្ធសភា ។

ជាមួយនេះដែរអង្គភាពទាំងអស់របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានកសាងនូវផែនការយុទ្ធសាស្ត្រ រយៈពេល៥ឆ្នាំ (២០០៨-២០១២) ដែលឆ្លើយតបទៅនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជារយៈពេល១០ឆ្នាំ (២០០៨-២០១៨) ។

ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការជាមួយនឹងរដ្ឋសភា អគ្គលេខាធិការដ្ឋាននៃសភាទាំងពីរ (ព្រឹទ្ធសភា និងរដ្ឋសភា) បានកសាងនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពសភាកម្ពុជា រយៈពេល១០ឆ្នាំ (២០០៨-២០១៨) ដែលជាត្រីវិស័យនៃដំណើរអភិវឌ្ឍព្រឹទ្ធសភា និងរដ្ឋសភាកម្ពុជា ។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភាបានសិក្សា និងកសាងប្លង់មេចំនួន ៥ ដើម្បីអភិវឌ្ឍស្ថាប័នមានដូចខាងក្រោម ៖

- ប្លង់មេសម្រាប់ការអភិវឌ្ឍសមត្ថភាពខាងច្បាប់
- ប្លង់មេសម្រាប់ការអភិវឌ្ឍបណ្ណាល័យ និងបណ្ណសារ
- ប្លង់មេសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន (ICT)
- ប្លង់មេសម្រាប់ការអភិវឌ្ឍការប្រាស្រ័យឆ្លើយឆ្លង
- ប្លង់មេសម្រាប់ការបណ្តុះបណ្តាលធនធានមនុស្ស ។

ដើម្បីឈានទៅសម្រេចប្លង់មេខាងលើ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានកសាងនូវផែនការយុទ្ធ-សាស្ត្ររយៈពេល ៦ឆ្នាំ (២០១២ - ២០១៨) បំនួនបីគឺ ៖

១.ផែនការយុទ្ធសាស្ត្រ ស្តីពីការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស នៃអគ្គលេខាធិការដ្ឋាន

ព្រឹទ្ធសភា ដែលលើកគោលដៅចំនួនបួន ផ្តោតលើ ៖

- ការកសាងសមត្ថភាពជំនាញឯកទេសដល់មន្ត្រីរាជការរបស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី លើវិស័យមុខងារនីតិកម្ម ត្រួតពិនិត្យ និងមុខងារជាតំណាង
- ពង្រឹងសមត្ថភាពមន្ត្រីរាជការរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គាធិការដ្ឋាន លើវិស័យជំនាញពាក់ព័ន្ធនឹងមុខងារគ្រប់គ្រង ផ្គត់ផ្គង់ធនធាន សវនកម្ម និងតម្រង់ទិស
- កសាងសមត្ថភាពជំនាញឯកទេសដល់មន្ត្រីរាជការរបស់អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ លើវិស័យមុខងារព័ត៌មាន ពិធីការ ទំនាក់ទំនងអន្តរជាតិ បច្ចេកវិទ្យាព័ត៌មាន បណ្ណាល័យ និងបណ្ណសារដ្ឋាន
- កសាងជារួមសមត្ថភាពជំនាញជាមូលដ្ឋាន និងចំណេះដឹងជាមូលដ្ឋានដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អំពីវប្បធម៌រដ្ឋបាល វប្បធម៌នយោបាយ និងវប្បធម៌ប្រជាធិបតេយ្យ និងនីតិរដ្ឋ។

២.ផែនការយុទ្ធសាស្ត្រ ស្តីពីការប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា រយៈពេល៦ឆ្នាំ (២០១២-២០១៨) ដែលលើកគោលដៅចំនួនប្រាំ ផ្តោតលើ ៖

- **ការអភិវឌ្ឍធនធានមនុស្ស** : លើកកម្ពស់សមត្ថភាពសមាជិក សមាជិកាព្រឹទ្ធសភា គណៈកម្មការជំនាញ មន្ត្រីជំនួយការ និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើជំនាញដែលពាក់ព័ន្ធដល់ការប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈ ដើម្បីធានាគុណភាពអាចឆ្លើយតបបានតាមតម្រូវការរបស់ព្រឹទ្ធសភា
- **ពង្រឹង និងពង្រីកតួនាទីភាពជាតំណាង** : បង្កើនទំនាក់ទំនងរបស់សមាជិកព្រឹទ្ធសភា និងបេសកកម្មជាប្រព័ន្ធទៅតាមមូលដ្ឋាន ដើម្បីជួបប្រាស្រ័យឆ្លើយឆ្លងជាមួយនឹងម្ចាស់ឆ្នោត និងសាធារណជននៅតាមភូមិភាគ
- **ការលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មាន** : លើកកម្ពស់ការរៀបចំប្រព័ន្ធឆ្លើយឆ្លងរបស់ព្រឹទ្ធសភា និងជំរុញការផ្សព្វផ្សាយព័ត៌មានអំពីកិច្ចការព្រឹទ្ធសភា ដើម្បីធានាបានលំហូរព័ត៌មានរបស់ស្ថាប័នជូនម្ចាស់ឆ្នោត និងសាធារណជន
- **ទំនាក់ទំនងសាធារណៈ:** : បង្កើនទំនាក់ទំនងជាមួយនឹងម្ចាស់ឆ្នោត រដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នក្រោមជាតិ ប្រព័ន្ធឃោសនា អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលឲ្យកាន់តែប្រសើរជាងមុន
- **កិច្ចសហប្រតិបត្តិការអន្តរជាតិ** : ជំរុញទំនាក់ទំនង និងកិច្ចសហការជាមួយនឹងដៃគូអភិវឌ្ឍន៍ សភាបរទេស និងម្ចាស់ជំនួយ ព្រមទាំងសភានៃប្រទេសជាមិត្តដើម្បីទទួលបានការគាំទ្រកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរបទពិសោធន៍ និងជំនួយសម្រាប់ការអភិវឌ្ឍស្ថាប័ន។

៣.ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍផ្នែកព័ត៌មានវិទ្យារបស់ព្រឹទ្ធសភា ដែលលើកគោលដៅចំនួនប្រាំពីរផ្តោតលើ ៖

-ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ដើម្បីធានាដល់ការស្រាវជ្រាវព័ត៌មាន
-គ្រប់គ្រងច្បាប់តាមប្រព័ន្ធអេឡិចត្រូនិក (E-legislative)
-បណ្ណាល័យទំនើប : ដើម្បីជាបង្អែករឹងមាំនៃការផ្តល់សេវាខាងការស្រាវជ្រាវ

-ប្រព័ន្ធគ្រប់គ្រងឯកសារ : ដើម្បីប្រែក្លាយឯកសារជាក្រដាស ទៅជាឯកសារអេឡិចត្រូនិក

-ប្រព័ន្ធធនធានមនុស្ស : ដើម្បីប្រែក្លាយការគ្រប់គ្រងធនធានមនុស្សពីលក្ខណៈសាមញ្ញ ទៅជាការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិក (Databases System)

-ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក

-ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីធានាបានការគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈតាមស្តង់ដារអន្តរជាតិ ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំ និងអនុវត្តនូវសេចក្តីសម្រេចរួម (ព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សាធម្មនុញ្ញ) និងគោលនយោបាយមួយចំនួន ដូចខាងក្រោម ៖

១. សេចក្តីសម្រេចរួម

- សេចក្តីសម្រេច លេខ : ០០៣ ព.រ.ក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែប្រែតម្លៃឯកតា (ពី៤០០ទៅ៦០០)នៃសន្ធស្សន៍បៀវត្សរ៍ មូលដ្ឋានរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- សេចក្តីសម្រេច លេខ : ០០៤ ព.រ.ក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែប្រែប្រាក់វិភាជន៍គ្រួសារប្រចាំខែរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- សេចក្តីសម្រេច លេខ : ០០៥ ព.រ.ក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- សេចក្តីសម្រេចលេខ : ០០៦ ព.រ.ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែប្រែតម្លៃឯកតាសន្ធស្សន៍ (ពី៦០០ទៅ៧២០)នៃបៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- សេចក្តីសម្រេចលេខ : ០០៧ ព.រ.ក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការកែប្រែតម្លៃឯកតាសន្ធស្សន៍(ពី៧២០ទៅ៨៧០)នៃបៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានរៀបចំ លក្ខន្តិកៈរួម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពី សមាគមសង្គហៈមន្ត្រីរាជការនៃក្រុមនីតិ-ប្បញ្ញត្តិ
- សេចក្តីសម្រេចលេខ : ០០៨ ព.រ.ក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ស្តីពីការកែប្រែតម្លៃឯកតាសន្ធស្សន៍ (៨៧០ទៅ១០៥០)នៃបៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ។

២. គោលនយោបាយ

- បន្តតាមដានត្រួតពិនិត្យ វាយតម្លៃលើការអនុវត្តនូវគោលនយោបាយមានស្រាប់ និងធ្វើការកែសម្រួលថ្មីក្នុងករណីចាំបាច់
- គោលនយោបាយស្តីពី ការជ្រើសរើសអ្នករាជការឲ្យចូលធ្វើការ
- គោលនយោបាយស្តីពី ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- គោលនយោបាយស្តីពី ការពិពណ៌នាការងារ
- គោលនយោបាយស្តីពី ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស
- គោលនយោបាយស្តីពីការជំរុញនិងលើកទឹកចិត្តដល់អ្នករាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- គោលនយោបាយចំពោះស្ត្រីក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- គោលនយោបាយស្តីពី ការតែងតាំងអ្នករាជការឲ្យកាន់មុខតំណែងគ្រប់គ្រងនៅក្នុងអង្គការលេខ

នៃរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- គោលនយោបាយស្តីពី របបសាធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់អ្នករាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- កសាងគោលនយោបាយស្តីពី ការទទួលខុសត្រូវរបស់អ្នកដឹកនាំ គ្រប់គ្រង
- កសាងគោលនយោបាយស្តីពី កាតព្វកិច្ចរបស់មន្ត្រីរាជការក្រុមនីតិប្បញ្ញត្តិនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

បន្ថែមលើនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំ ៖

- កែប្រែបទបញ្ជាផ្ទៃក្នុងថ្មីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងមានសេចក្តីសម្រេច ស្តីពីការប្រកាសឲ្យប្រើ លេខ០០៦/១២១០/ពស/សរ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១០
- កែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- គោលនយោបាយស្តីពី ការផ្តល់ប្រាក់កម្រៃ និងប្រាក់បាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់បុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- សេចក្តីសម្រេចស្តីពីគោលការណ៍អំពី នីតិវិធីប្រតិបត្តិការរបស់អធិការដ្ឋានគ្រប់គ្រងផ្ទៃក្នុង និងហិរញ្ញវត្ថុនៃអគ្គាធិការដ្ឋាន
- កម្មវិធីការងារត្រួតពិនិត្យរបស់អធិការដ្ឋានគ្រប់គ្រងផ្ទៃក្នុង និងហិរញ្ញវត្ថុនៃអគ្គាធិការដ្ឋាន
- បែបបទការងារទូទៅរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- គោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ ៖
  - គោលការណ៍ស្តីពីការកំណត់សិទ្ធិបញ្ជាចំណាយថវិការបស់ព្រឹទ្ធសភា ដែលមិនមានចែងក្នុងគោលការណ៍ហិរញ្ញវត្ថុ និងបែបបទនីតិវិធីស្នើសុំការចំណាយថវិកា
  - គោលការណ៍ស្តីពី ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់សមាជិក សមាជិកាព្រឹទ្ធសភា
  - គោលការណ៍ស្តីពី ប្រាក់បំណាច់បន្ថែមលើប្រាក់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា
  - គោលការណ៍ស្តីពី របបបេសកកម្មក្នុងប្រទេសរបស់សមាជិកព្រឹទ្ធសភា គណៈកម្មការជំនាញ និងគណៈកម្មការនានា
  - គោលការណ៍ស្តីពី របបបន្ថែមនូវប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់សកម្មភាពរបស់គណៈកម្មការជំនាញ និងគណៈកម្មការនានានៃព្រឹទ្ធសភា
  - គោលការណ៍ស្តីពី របបបេសកកម្មក្រៅប្រទេសរបស់សមាជិក សមាជិកាព្រឹទ្ធសភា
  - គោលការណ៍ស្តីពី ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌរបស់សមាជិក សមាជិកាព្រឹទ្ធសភា
  - គោលការណ៍ស្តីពី ប្រាក់អន្តរាគមន៍លើវិស័យសង្គមកិច្ចប្រចាំខែ របស់ថ្នាក់ដឹកនាំព្រឹទ្ធសភា
  - គោលការណ៍ស្តីពី របបធានាគារបង់រងសង្គមកិច្ចប្រចាំខែរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា
  - គោលការណ៍ស្តីពី របបប្រាក់ទទួលខុសត្រូវបន្ថែមលើប្រាក់សង្គមកិច្ចជូនថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់បំណាច់ប្រចាំខែរបស់អ្នកឯកទេសជាន់ខ្ពស់អមប្រធានគណៈកម្មការជំនាញនៃព្រឹទ្ធសភា
  - គោលការណ៍ស្តីពី ប្រាក់បំណាច់មុខងារជំនួយការ និងអ្នកបើកបររបស់សមាជិក សមាជិកាព្រឹទ្ធសភា
  - គោលការណ៍ស្តីពី របបឧបត្ថម្ភគោលនយោបាយលើកទឹកចិត្តជូនសមាជិក សមាជិកាព្រឹទ្ធសភា

ដែលជាសមាជិកគណៈកម្មការពិសេស ឬគណៈកម្មការចំពោះកិច្ចក្នុងការកសាងគោលនយោ-បាយ បទដ្ឋានការងារ និងឯកសារនានាសម្រាប់ជាប្រយោជន៍របស់ព្រឹទ្ធសភា

- គោលការណ៍ស្តីពី សេវាថវិកាសម្រាប់គេហដ្ឋាន និងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា
- គោលការណ៍ស្តីពី ការកំណត់របបវត្ថុអនុស្សាវរីយ៍ និងផ្តាប្រើប្រាស់ជាផ្លូវការ នៅព្រឹទ្ធសភា សម្រាប់ជូនភ្ញៀវជាតិ អន្តរជាតិ និងពិធីនានា
- គោលការណ៍ស្តីពី ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌរបស់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋាន
- គោលការណ៍ស្តីពី ប្រាក់ពិនិត្យ និងព្យាបាលជំងឺរបស់ថ្នាក់ដឹកនាំនៃអង្គភាពចំណុះអគ្គលេខា ធិការដ្ឋានព្រឹទ្ធសភា
